API
BUILDING CAPACITY FOR CHANGE

## វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ




# របាយការណ៍ បីឆ្នាំ

# ២០១៩-២០២១

ការពិនិត្យមើលពាក់កណ្ដាលយុទ្ធសាស្ត្រ ឆ្នាំ២០១៩-២៣

# មាតិកា


១ របកគំហើញសង្ខេប និងអនុសាសន៍នានា ..... ៣

២ ការសម្រេចបាននៃផែនការយុទ្ធសាស្រ្ត (លទ្ធផលនានា) មកដល់បច្ចុប្បន្ន ..... ៥

គោលបំណងយុទ្ធសាស្រ្ត/លទ្ធផលយុទ្ធសាស្រ្តទី១៖ ការដាក់ឥទ្ធិពលលើគោលនយោបាយ ..... ៥

គោលបំណងយុទ្ធសាស្រ្ត/លទ្ធផលយុទ្ធសាស្រ្តទី២៖ ការចូលរួមរបស់ប្រជាពលរដ្ឋ ..... ៨

គោលបំណងយុទ្ធសាស្រ្ត/លទ្ធផលយុទ្ធសាស្រ្តទី៣៖ ធ្វើឱ្យសិទ្ធិទទួលបានព័ត៌មានប្រសើរឡើង ..... ១២

គោលបំណងយុទ្ធសាស្រ្ត/លទ្ធផលយុទ្ធសាស្រ្តទី៤៖ ការអភិវឌ្ឍអង្គការរបស់ API ..... ១៤

៣ អនុសាសន៍សម្រាប់អនាគត ..... ២០

# របាយការណ៍បីឆ្នាំ ២០១៩-២១

## ១ របកគំហើញសង្ខេប និងអនុសាសន៍នានា

យោងតាមលទ្ធផលជាច្រើននៃការវាយតម្លៃពាក់កណ្តាលយុទ្ធសាស្ត្រ ឆ្នាំ២០១៩-២៣

### ការរីកចម្រើននៃលទ្ធផលទី១៖ ការដាក់ឥទ្ធិពលលើគោលនយោបាយ

API បានអនុវត្តវិធីតស៊ូមតិបែបទន់មួយ (ដូចជា ការចូលរួមក្នុងកិច្ចសន្ទនាជាងការប្រឈមមុខដាក់គ្នា) ដើម្បីតស៊ូមតិជាមួយរដ្ឋាភិបាលដើម្បីបង្កើត/ធ្វើវិសោធនកម្មច្បាប់/គោលនយោបាយចំនួន៨។ API បានជ្រើសរើសអង្គការសហគមន៍ (CBO) ចំនួន ១៧០ មកធ្វើការកសាងសមត្ថភាពស្ថាប័នរបស់ពួកគាត់ និងគាំទ្រពួកគាត់ក្នុងការធ្វើការតស៊ូមតិជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។ មានបញ្ហាចំនួន ២៧៣ ត្រូវបាន និងកំពុងបានលើកឡើងដោយអង្គការសហគមន៍ ហើយបញ្ហាចំនួន១៣១ (៤៨%) បានដោះស្រាយដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ។

#### អនុសាសន៍នានាសម្រាប់លទ្ធផលទី១៖

- ត្រូវត្រៀមឱ្យបានរួចរាល់សម្រាប់សកម្មភាពបន្ទាប់នានានៅពេលដែលច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន (A2I) ត្រូវបានអនុម័ត។

### ការរីកចម្រើននៃលទ្ធផលទី២៖ ការចូលរួមរបស់ប្រជាពលរដ្ឋ

គួរឱ្យកត់សម្គាល់ មានអង្គការសហគមន៍ (CBO) ចំនួន១៦៩ (ក្នុងចំណោម១៧០) បានបង្កើត និងអនុវត្តផែនការតស៊ូមតិជាច្រើន និងគម្រោងខ្នាតតូចចំនួន៥០ ដែលបានអនុវត្តដោយសមាជិកសមាគមក្រុមប្រឹក្សាមូលដ្ឋានខេត្ត (PALC) ដើម្បីដោះស្រាយបញ្ហា/តម្រូវការដែលបានចាត់អាទិភាពនានារបស់អ្នកក្រីក្រ និងក្រុមងាយរងគ្រោះបំផុតជាច្រើនក្រុម។

ការសិក្សាដើមគ្រាឆ្នាំ ២០១៩ បានបញ្ជាក់ថាមានអ្នកផ្តល់ចម្លើយ៣៨% បានពេញចិត្តនឹងការបំពេញការងាររបស់រដ្ឋបាលមូលដ្ឋាន ដែលផ្តល់សេវាសាធារណៈជាច្រើនដែលលឿន និងទុកចិត្តបានជាងមុនដល់ប្រជាពលរដ្ឋនានា។ ការអង្កេតតាមអនឡាញ ឆ្នាំ ២០២១ បានបង្ហាញថាមានអ្នកផ្តល់ចម្លើយ៨០% បានប៉ាន់ប្រមាណថាគុណភាពនៃការបំពេញការងារ/សេវាផ្សេងៗគឺមានភាពប្រសើរឡើង មានក្រុមប្រឹក្សា៩៦% បានរាយការណ៍ថា មានអង្គការសហគមន៍បានចូលរួមក្នុងសកម្មភាពត្រួតពិនិត្យជាច្រើនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ តំណាងអង្គការសហគមន៍៨១% បានបញ្ជាក់ថាពួកគាត់បានធ្លាប់ត្រួតពិនិត្យសកម្មភាពដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

#### អនុសាសន៍នានាសម្រាប់លទ្ធផលទី២៖

- គាំទ្រតំណាងប្រជាពលរដ្ឋជាច្រើននាក់ដើម្បីទទួលបានជម្រើសល្អបំផុត (រួមទាំងប្រព័ន្ធ ICT) ដើម្បីចូលពាក់ព័ន្ធដោយប្រសិទ្ធភាពជាមួយរដ្ឋបាលមូលដ្ឋាន
- ចម្លងតាម/ពង្រីកការដោះស្រាយបញ្ហាគំរូ ISAF
- បន្តជួយកសាងសមត្ថភាពអង្គការសហគមន៍សម្រាប់តស៊ូមតិដោយប្រសិទ្ធភាព និងភ្ជាប់ពួកគាត់ជាមួយបណ្តាញច្រើនប្រភេទ។
- ដាក់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធក្នុងកម្មវិធីកសាងសមត្ថភាពអង្គការសហគមន៍នានាដើម្បីឱ្យប្រតិបត្តិការល្អប្រសើរ។
- ស្វែងរកការផ្តល់មូលនិធិដើម្បីគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិឱ្យពង្រីកកិច្ចប្រជុំចល័ត និងតាមយន្តការអនឡាញ និងប្រើប្រាស់ដល់អតិបរមានូវប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីលើកស្ទួយការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋច្រើននាក់។

# របាយការណ៍បីឆ្នាំ ២០១៩-២១

## ការរីកចម្រើននៃលទ្ធផលទី៣៖ ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពប្រើប្រាស់ព័ត៌មាន

មានប្រជាពលរដ្ឋចំនួន ៤៨៥,១៤០នាក់ (ស្រីចំនួន២០២,៨៣៥នាក់) បានចូលរួមក្នុងការលើកស្ទួយការយល់ដឹងអំពីប្រធានបទខុសៗគ្នាដែលរៀបចំដោយ API។ ប្រជាពលរដ្ឋចំនួន៣១,៧១១នាក់បានចូលប្រើប្រាស់ព័ត៌មានសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ស្ថាប័នសាធារណៈទាំងអស់ដែលបានដាក់ជាគោលដៅនោះ (មាន៦៧៨ ១០០%) បានបើកចំហព័ត៌មានដល់សាធារណជន។ តាមរយៈការអង្កេតតាមអនឡាញ គឺមានអ្នកផ្តល់ចម្លើយ៤៩% ធ្លាប់ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាឃុំ និង៤៧% ធ្លាប់ចូលរួមកិច្ចប្រជុំស្រុក/ក្រុង។

### អនុសាសន៍នានាសម្រាប់លទ្ធផលទី៣៖

- បង្កើតផែនការចីរភាពនានាសម្រាប់យន្តការឌីជីថលដែលមានស្រាប់ទាំងអស់។
- ស្នើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបើកចំហព័ត៌មានសំខាន់ៗ (រួមទាំង ផែនការអភិវឌ្ឍន៍សហគមន៍អាទិភាពរយៈពេលវែង) ធ្វើឱ្យមធ្យោបាយបើកចំហព័ត៌មានមានលក្ខណៈសាមញ្ញ និងប្រសើរឡើង។

## ការរីកចម្រើននៃលទ្ធផលទី៤៖ ការអភិវឌ្ឍអង្គការ

API ត្រូវបានប្រគល់កិត្តិយសជាវិញ្ញាបនបត្រនៃក្រុមអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ (GPP certificate) ក្នុងឆ្នាំ២០១៩។ API គឺគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល (BoD) ដែលដំណើរការតាមលក្ខន្តិកៈ និងគោលនយោបាយជាច្រើន។ នៅឆ្នាំ២០២១ API បានចុះកិច្ចសន្យាជួលមន្ត្រីឯកទេសខាងត្រួតពិនិត្យ និងវាយតម្លៃ (MEAL specialist) ដើម្បីធ្វើឱ្យប្រព័ន្ធត្រួតពិនិត្យ វាយតម្លៃ គណនេយ្យភាព និងការរៀនសូត្រ (MEAL template) របស់ខ្លួនមានស្តង់ដារ មូលនិធិរបស់ API បានកើនឡើង៥៦% ក្នុងឆ្នាំ២០២០ និង ២៨% ក្នុងឆ្នាំ២០២១។ បុគ្គលិក API បានកើនឡើងពី១៨នាក់ទៅ៣៤នាក់ (៨៩%) ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២១ ប៉ុន្តែកម្រិតបុគ្គលិកលាឈប់នៅតែជាការលំបាកមួយដដែល។

### អនុសាសន៍នានាសម្រាប់លទ្ធផលទី៤៖

- ធ្វើបច្ចុប្បន្នភាពលក្ខន្តិកៈ (ក្បួនក្រុមប្រឹក្សាភិបាល (BoD manual)) និងបង្កើតយន្តការឯករាជ្យមួយសម្រាប់ក្រុមប្រឹក្សាភិបាលប្រាស្រ័យទាក់ទងផ្ទាល់ជាមួយអ្នកពាក់ព័ន្ធជាច្រើន។
- ធ្វើបច្ចុប្បន្នភាពគោលនយោបាយធនធានមនុស្ស ជាពិសេស យន្តការវាយតម្លៃបុគ្គលិក។
- ធ្វើបច្ចុប្បន្នភាពគោលនយោបាយហិរញ្ញវត្ថុដើម្បីឆ្លុះបញ្ចាំងវិធីធ្វើការតាមអនឡាញ ធ្វើឱ្យសាមញ្ញនូវនីតិវិធីលទ្ធកម្ម និងភស្តុភារ (រួមទាំង សំណើ និងការទូទាត់តាមអនឡាញ) និងធ្វើឱ្យមានស្តង់ដារនូវការបង់ប្រាក់ឧបត្ថម្ភ ស្របគ្នានឹងការបង្កើតគោលនយោបាយមួយស្តីពីការលៃលកតម្លៃបដិភាគ (shared cost)។
- ធ្វើប្រតិភូកម្មអំណាចច្រើនថែមទៀតដល់បុគ្គលិកក្នុងការធ្វើការសម្រេចចិត្ត។
- ឱ្យបុគ្គលិកមូលដ្ឋានចូលពាក់ព័ន្ធជាមួយដំណើរការធ្វើស្តង់ដារប្រព័ន្ធត្រួតពិនិត្យ វាយតម្លៃ គណនេយ្យភាព និងរៀនសូត្រ (MEAL template) រួមទាំងការពិនិត្យឡើងវិញ/ការអភិវឌ្ឍឧបករណ៍ប្រមូលទិន្នន័យជាច្រើនដែលបម្រើឱ្យគោលបំណងជាក់លាក់ជាច្រើន និងដាក់ពួកគាត់ឱ្យពាក់ព័ន្ធក្នុងការឆ្លុះបញ្ចាំងទៀងទាត់មួយ។
- ធ្វើការសិក្សាអំពីភាពអាចទៅរួច និងវិភាគអំពីប្រសិទ្ធភាព និងប្រសិទ្ធផលនៃការបង្កើតការិយាល័យ API នៅតាមតំបន់របស់គម្រោង។

# របាយការណ៍បីឆ្នាំ ២០១៩-២១

## ២ ការសម្រេចបាននៃផែនការយុទ្ធសាស្ត្រ (លទ្ធផលនានា) មកដល់បច្ចុប្បន្ន

ផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩-២០២៣ របស់ API មានលទ្ធផលយុទ្ធសាស្ត្រចំនួនបួន។ លទ្ធផលនីមួយៗបានកំណត់សូចនាករ និងគោលដៅជាច្រើនដើម្បីធ្វើឱ្យបានសម្រេច។ ការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ API និងគម្រោងរបស់វាត្រូវបានប៉ះពាល់ដោយការរីករាលដាលជំងឺកូវីដ-១៩។ ដូចបានជម្រាបជូនពីដំបូងមកហើយ ក្រុមវាយតម្លៃទទួលបានប្រភពទិន្នន័យ និងព័ត៌មានចម្បងៗចំនួនពីរជាគ្រឹះនៃការវិភាគរបស់ក្រុមវាយតម្លៃ។ ក្រុមបានផ្តុំជាបឋមមុននូវទិន្នន័យរង (secondary data) ដែលដកស្រង់ពីការពិនិត្យមើលឯកសារ ជាមួយនឹងទិន្នន័យចម្បង (primary data) ប្រមូលបានមកពីអ្នកផ្តល់ចម្លើយពាក់ព័ន្ធជាច្រើននាក់តាមរយៈការសម្ភាសន៍ជនបង្គោល (KIIs) ក្រុមពិភាក្សាចំណាប់អារម្មណ៍ (FGDs) ការអង្កេតតាមអនឡាញ និងកិច្ចប្រជុំឆ្លុះបញ្ចាំង។ របកគំហើញបានបញ្ជាក់ថា កម្រិតនានានៃការសម្រេចបានជាច្រើន និងតំបន់ដែលគេយកចិត្តទុកដែលត្រូវបានផ្តល់អនុសាសន៍ឱ្យដោះស្រាយសម្រាប់ការធ្វើផែនការ និងការអនុវត្តនាអនាគត។

### គោលបំណងយុទ្ធសាស្ត្រ/លទ្ធផលយុទ្ធសាស្ត្រទី១៖ ការដាក់ឥទ្ធិពលលើគោលនយោបាយ

ការពិនិត្យឯកសារ និងអង្កេតតាមអនឡាញ[1] បានតាមដានទិន្នផលជាច្រើនដែលគម្រោង API ជាច្រើនកំពុងបានបង្កើតឡើងធៀបនឹងសូចនាករដែលបានដាក់ផែនការរបស់វា។ លទ្ធផលនានាគឺបង្ហាញក្នុងតារាង៤ខាងក្រោម៖

**តារាង១៖ សង្ខេបលទ្ធផលទី១៖ ការដាក់ឥទ្ធិពលលើគោលនយោបាយ**

| **លទ្ធផលទី១៖** ដាក់ឥទ្ធិពលលើការបង្កើតគោលនយោបាយ និងការអនុវត្តដើម្បីដោះស្រាយសិទ្ធិ និងតម្រូវការនានារបស់ក្រុមងាយរងគ្រោះបំផុតជាច្រើន និងធានាឱ្យមានលំហប្រជាធិបតេយ្យសម្រាប់ស្ត្រី និងបុរសដើម្បីអនុវត្តសិទ្ធិរបស់ពួកគេ។ | |
|---|---|
| **សូចនាករនានាសម្រាប់វាស់វែងលទ្ធផលទី១៖** | **សង្ខេបលទ្ធផលធៀបនឹងសូចនាករ (២០១៩-២០២១)** |
| • ចំនួនច្បាប់ និងគោលនយោបាយនានាដែលបានដាក់ និងកំពុងទទួលឥទ្ធិពលសម្រាប់ផលប្រយោជន៍ល្អបំផុតរបស់យុវជន ស្ត្រី និងក្រុមងាយរងគ្រោះត្រូវបានគេជជែក អនុម័ត និងអនុវត្តដោយមានប្រសិទ្ធភាព។ | • ច្បាប់/គោលនយោបាយចំនួន៨ ត្រូវបានតស៊ូមតិដើម្បីបង្កើត/អនុម័តតាមរយៈកិច្ចសន្ទនាតស៊ូមតិមួយស៊េរី។ |
| • ចំនួនអង្គការសហគមន៍ ចំនួនយុវជន និងចំនួនក្រុមងាយរងគ្រោះត្រូវបានពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពប្រតិបត្តិការ និងជំនាញបច្ចេកទេសខាងត្រួតពិនិត្យថវិកាសាធារណៈ ការបំពេញការងារ ការអនុវត្ត គោលនយោបាយ ការផ្តល់សេវាសាធារណៈ និងការវិនិយោគវិស័យសាធារណៈដែលប៉ះពាល់ដល់សិទ្ធិ និងជីវភាពសហគមន៍។ | • API បានកសាងសមត្ថភាពអង្គការសហគមន៍ចំនួន១៧០ ក្នុងវិស័យតស៊ូមតិ ចំណេះដឹងខាងច្បាប់ អភិបាលកិច្ចមូលដ្ឋាន និងការធ្វើផែនការ និងការធ្វើថវិកាមូលដ្ឋាន។<br>• API បានគាំទ្រអង្គការសហគមន៍ទាំងនោះក្នុងការធ្វើការតស៊ូមតិជាមួយអាជ្ញាធរមូលដ្ឋាននានាដើម្បីដោះស្រាយបញ្ហាសហគមន៍របស់ពួកគេ និងត្រួតពិនិត្យថវិកាសាធារណៈ ការអនុវត្តគោលនយោបាយ ការផ្តល់សេវាសាធារណៈ និងការវិនិយោគវិស័យឯកជនដែលប៉ះពាល់ដល់សិទ្ធិ និងជីវភាពសហគមន៍។ |
| • ចំនួនបញ្ហាសហគមន៍ដែលប៉ះពាល់អវិជ្ជមានដោយចំណុចខ្វះខាតក្នុងការអនុវត្តច្បាប់/គោលនយោបាយដែលបានកំណត់ឃើញ និងបានតស៊ូមតិសម្រាប់ឬដោយយុវជន ស្ត្រី និងក្រុមងាយរងគ្រោះជាច្រើន និងដោះស្រាយ/គិតគូដោយស្ថាប័នថ្នាក់ក្រោមជាតិ និងស្ថាប័នរាជរដ្ឋាភិបាលថ្នាក់ជាតិនានា។ | • បញ្ហាចំនួន២៧៤ ត្រូវបានលើកឡើង និងបញ្ហាចំនួន១៣១ (៤៨%) ត្រូវបានដោះស្រាយដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធនានា។<br>• តាមរយៈការអង្កេតតាមអនឡាញ[2] ៦៩%នៃអ្នកផ្តល់ចម្លើយបានលើកបញ្ហាជាច្រើន[3] ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និង៨២%នៃពួកគេបាននិយាយថារដ្ឋបាលថ្នាក់ក្រោមជាតិបានគិតគូអំពីបញ្ហាដែលបានលើក ហើយពួកគេបានពេញចិត្តនឹងសកម្មភាពទាំងឡាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដោះស្រាយបញ្ហាជាច្រើនដែលបានលើកឡើងដោយប្រជាពលរដ្ឋ។ |

# របាយការណ៍បីឆ្នាំ ២០១៩-២១

លទ្ធផលជាច្រើនដែលបានមកពីការពិនិត្យមើលឯកសារបានបង្ហាញថា API បានធ្វើឱ្យមានការរីកចម្រើនធៀបនឹងសូចនាករចំនួន៣សម្រាប់លទ្ធផលទីមួយនៃផែនការយុទ្ធសាស្ត្ររបស់វា ឆ្នាំ២០១៩–២០២៣។ ដំបូងបំផុត API បាន និងកំពុងអនុវត្តកិច្ចសន្ទនាតស៊ូមតិមួយស៊េរី និងបានចូលរួមជាមួយអ្នកពាក់ព័ន្ធដទៃទៀតដើម្បីផ្តល់ធាតុចូលនានា ក៏ដូចជាដើម្បីជជែកអំពីការអភិវឌ្ឍ និង/ឬការធ្វើឱ្យប្រសើរឡើងនូវច្បាប់/គោលនយោបាយចំនួន៨ ដើម្បីចំណេញដល់អ្នកក្រីក្រ និងក្រុមដែលគេមិនអើរពើនៅប្រទេសកម្ពុជា។ ច្បាប់/គោលនយោបាយទាំងនោះរួមបញ្ចូលទាំង៖

- ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន (A2I)[4] មានបំណងធ្វើឱ្យប្រជាពលរដ្ឋកម្ពុជានានាអាចទទួលបានព័ត៌មានសុក្រិត និងទុកចិត្តបានដើម្បីធ្វើការសម្រេចចិត្តដែលមានព័ត៌មានគ្រប់គ្រាន់។
- អនុក្រិតស្តីពីការផ្ទេរមុខងារ (ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ) កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ឆ្នាំ២០២១-២០៣០ និងច្បាប់ស្តីពីថវិកាជាតិឆ្នាំ២០២១។
- គោលការណ៍ណែនាំអំពីការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម (ISAF) ដើម្បីគិតគូអំពីបញ្ហាសំខាន់ៗដែលធ្វើឱ្យមានការបារម្ភដល់ជនមានពិការភាព (PWD)។
- គោលការណ៍ណែនាំអំពី ISAF សម្រាប់សេវាគាំពារសង្គម។
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន និគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ។
- គោលការណ៍ណែនាំអំពីមុខងារ និងការផ្តល់សេវារបស់ការិយាល័យច្រកចេញចូលតែមួយ (OWSO) អង្គភាពច្រកចេញចូលតែមួយ (OWSU) និងតំណាងប្រជាពលរដ្ឋថ្នាក់ស្រុក (DO)។
- ការធ្វើវិសោធនកម្មច្បាប់ស្តពីសមាគម និងអង្គការ។
- ការពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ និងការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងស្រវឹង។

ទីពីរ API បាន និងកំពុងកសាងសមត្ថភាពអង្គការសហគមន៍ចំនួន១៧០ ក្នុងវិស័យតស៊ូមតិ ចំណេះដឹងខាងច្បាប់ អភិបាលកិច្ចមូលដ្ឋាន និងការធ្វើផែនការ និងការធ្វើថវិកាមូលដ្ឋាន។ API ក៏បានគាំទ្រផងដែរដល់អង្គការសហគមន៍ទាំងនោះដើម្បីធ្វើការតស៊ូមតិជាមួយអាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយបញ្ហាសហគមន៍នានា និងដើម្បីត្រួតពិនិត្យថវិកាសាធារណៈ ការអនុវត្តគោលនយោបាយ ការផ្តល់សេវាសាធារណៈ និងការវិនិយោគវិស័យឯកជនដែលប៉ះពាល់សិទ្ធិ និងជីវភាពរបស់សហគមន៍។ អង្គការសហគមន៍ទាំងនោះរួមមាន៖

- អង្គការសហគមន៍ចំនួន៨៥ ធ្វើការលើបញ្ហាតាមវិស័យ ដោយមានសមាជិកចំនួន៦,៨០០នាក់ (រួមទាំងស្ត្រីចំនួន៤,៥៩០នាក់) ក្នុងខេត្តពោធិ៍សាត់ បន្ទាយមានជ័យ កំពង់ធំ កំពង់ស្ពឺ កណ្តាល និងកែប។





# របាយការណ៍បីឆ្នាំ ២០១៩-២១

- មានក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF) ចំនួន៣៥ក្រុម (ភាគច្រើនជាយុវជនជនជាតិដើមភាគតិច) ដែលមានសមាជិកចំនួន៦០២នាក់ (ស្ត្រីចំនួន៣៨៤នាក់) នៅក្នុងស្រុក និងក្រុងចំនួន៣៥ក្នុងខេត្តចំនួន៦ (រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ កោះកុង និងកណ្តាល) និងភ្នំពេញដើម្បីតស៊ូមតិស្តីពីគណនេយ្យភាពសង្គម (សម្រាប់សាលាបឋមសិក្សា មណ្ឌលសុខភាព ឃុំ/សង្កាត់ និងខណ្ឌ) និងការធ្វើឱ្យប្រសើរឡើងនូវសេវាឃុំ និងសេវាគាំពារសង្គម។
- មានអង្គការសហគមន៍ចំនួន៣៣ ដែលមានសមាជិកចំនួន៩០នាក់ជាស្ត្រីជនជាតិដើមភាគតិចនៅក្នុងស្រុកចំនួនបី រួមមាន ចិត្របុរី សាលាវិស័យ និងភ្នំក្រវ៉ាញ (ក្នុងខេត្តក្រចេះ កំពង់ស្ពឺ និងពោធិ៍សាត់)។
- មានទូតសុឆន្ទៈយុវជនចំនួន៨ក្រុមដែលមានសមាជិកចំនួន១០៨នាក់ (រួមទាំងស្ត្រីចំនួន៧២នាក់) ក្នុងស្រុកចំនួន៥ (នៃខេត្តបាត់ដំបង) និងក្រុងចំនួន៣១ (ក្នុងខេត្តកំពង់ឆ្នាំង ហើយ២ទៀតនៅខេត្តបន្ទាយមានជ័យ) ដើម្បីលើកស្ទួយការយល់ដឹង និងត្រួតពិនិត្យសេវាដែលផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយ (OWSO)។
- មានក្រុមយុវជនចំនួន៤ដែលមានសមាជិកចំនួន៨២នាក់ (រួមទាំងស្ត្រីចំនួន៥៣នាក់) ក្នុងការធ្វើផែនការ និងការធ្វើថវិកាមូលដ្ឋាន (ក្នុងស្រុកចំនួន៤នៃខេត្តកណ្តាល ភ្នំពេញ ក្រចេះ)។
- មានក្រុមស្ត្រីអ្នកលក់ដូរតាមដងផ្លូវចំនួន៣ក្រុមដែលមានសមាជិកចំនួន៥៩នាក់ (នៅភ្នំពេញ បាត់ដំបង និងសៀមរាប) ដើម្បីតស៊ូមតិ/លើកស្ទួយសិទ្ធិសេដ្ឋកិច្ចសង្គមសម្រាប់អាជីវកម្មខ្នាតតូច (micro-business)។
- មានក្រុមជនមានពិការភាពចំនួន១ក្រុមដែលមានសមាជិក១៧នាក់ (រួមទាំងស្ត្រីចំនួន២នាក់) នៅស្រុកត្រាំកក់ (ខេត្តតាកែវ)។
- មានបណ្តាញយុវជនចំនួន១ ដែលធ្វើការលើច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដែលមានសមាជិកចំនួន៥០នាក់ (រួមទាំងស្ត្រីចំនួន២៥នាក់) មកពីខេត្តទាំងអស់ចំនួន២៥ខេត្តនៅប្រទេសកម្ពុជា។

ទីបី API បាន និងកំពុងគាំទ្រអង្គការសហគមន៍ និងតំណាងប្រជាពលរដ្ឋជាច្រើននាក់ដើម្បីកំណត់អាទិភាពបញ្ហា និងបង្កើតផែនការតស៊ូមតិជាច្រើនដើម្បីលើកឡើងនូវបញ្ហាដែលបានកំណត់ទាំងនោះដល់ស្ថាប័នរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់។[5] មានបញ្ហាចំនួន ២៧៤ ត្រូវបានលើកឡើង និងបញ្ហាចំនួន ១៣១ (៤៨%) ត្រូវបានដោះស្រាយដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ។

- មានបញ្ហាចំនួន៧/៧ ត្រូវបានលើកឡើង/ដោះស្រាយ ដែលទាក់ទងនឹងតម្រូវការបញ្ចេញមតិយោបល់ និងតម្រូវការរូបវន្តនៃជនមានពិការភាព (PWDs)។
- មានបញ្ហាចំនួន៦៩/៦៩ត្រូវបានលើកឡើង/ដោះស្រាយ ដែលទាក់ទងនឹងការបំពេញការងារ/សេវាដែលមានគុណភាពនៅការិយាល័យច្រកចេញចូលតែមួយ/អង្គភាពច្រកចេញចូលតែមួយ (OWSO/OWSU)។ បញ្ហាចំនួន២៥ដែលនៅសល់គឺមិនត្រូវបានដោះស្រាយទេដោយសារនៅក្រៅសមត្ថកិច្ច ឬមិនពាក់ព័ន្ធនឹងការិយាល័យច្រកចេញចូលតែមួយ/អង្គភាពច្រកចេញចូលតែមួយ (OWSO/OWSU)។
- មានបញ្ហាចំនួន១៦/១៦ត្រូវបានលើកឡើងន/ដោះស្រាយ ដែលទាក់ទងនឹងសកម្មភាពអាទិភាពនានានៅក្នុងផែនការសកម្មភាពកម្រិតឃុំជាច្រើន និងថវិកាមូលដ្ឋានដែលរៃអង្គាសបាន (ដូចជា ពីវិស័យឯកជន UN/NGOs/CBOs និងអាជ្ញាធរមូលដ្ឋាន។
- មានបញ្ហាចំនួន២០/២០ត្រូវបានលើកឡើង/ដោះស្រាយ ដែលទាក់ទងនឹងយុវជនដែលទាមទារឱ្យបញ្ចូលសេវាគាំពារសង្គមទៅក្នុងផែនការវិនិយោគឃុំ (CIP)។
- មានបញ្ហាចំនួន១១៧/១៣ត្រូវបានលើកឡើង/ដោះស្រាយ ដែលទាក់ទងនឹងបញ្ហាសហគមន៍ដែលប៉ះពាល់ជនជាតិដើមភាគតិច ជាពិសេសស្ត្រីជនជាតិដើមភាគតិច។
- មានបញ្ហាចំនួន១៨/៦ត្រូវបានលើកឡើង/ដោះស្រាយ ដែលទាក់ទងនឹងសហគ្រិនស្ត្រីវ័យក្មេង (YWE)។

# របាយការណ៍បីឆ្នាំ ២០១៩-២១

តាមរយៈការអង្កេតតាមអនឡាញ[6] មានអ្នកផ្ដល់ចម្លើយ៦៩% (ដែលជាយុវជន ប្រជាពលរដ្ឋ និងតំណាងអង្គការសហគមន៍ជាច្រើននាក់) បញ្ជាក់ថាពួកគេបានលើកឡើងនូវបញ្ហាជាច្រើន[7] ដល់ស្ថាប័នថ្នាក់ក្រោមជាតិ និងស្ថាប័នរដ្ឋាភិបាលនានា។ ៨២% នៃពួកគេបាននិយាយថារដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នរដ្ឋាភិបាលជាច្រើនបានដោះស្រាយបញ្ហាផ្សេងៗដែលត្រូវបានលើកឡើង ហើយមាន១១%នៃពួកគេគឺពេញចិត្តខ្លាំង ៣៥%ពេញចិត្ត និង៣៦%ពេញចិត្តល្មមចំពោះសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នរដ្ឋាភិបាលថ្នាក់ជាតិនានាក្នុងការដោះស្រាយបញ្ហាដែលបានលើកឡើងដោយសហគមន៍នានា។

តាមរយៈសម្ភាសន៍ជនបង្គោល (KIIs) និងការពិភាក្សាក្រុមចំណាប់អារម្មណ៍ (FGDs) ក្រុមប្រឹក្សាភិបាលរបស់ API និងអ្នកតំណាងជាច្រើននាក់មកពី CPDD DCA EWMI និង NCDD-S ពេញចិត្តចំពោះការរួមចំណែកដ៏ធំធេងជាច្រើនរបស់ API ទៅក្នុងសេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលបានព័ត៌មាន (A2I)។[8] អ្នកតំណាងមកពីលេខាធិការដ្ឋាន NCDD-S ពេញចិត្ត API ចំពោះការធ្វើការជិតដិតជាមួយរដ្ឋាភិបាលក្នុងការត្រួតពិនិត្យភាពរីកចម្រើននៃគោលដៅអភិវឌ្ឍន៍យុទ្ធសាស្ត្រ (SDGs)[9] និងការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គមដំណាក់កាលទី១ (ISAF-I) និងគណនេយ្យភាពសង្គមដំណាក់កាលទី២ (ISAF-II) ក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា។

ក្នុងអំឡុងពេលនៃការពិភាក្សាក្រុមចំណាប់អារម្មណ៍ (FGDs) អ្នកផ្ដល់ចម្លើយភាគច្រើនបំផុតបានបញ្ជាក់ច្បាស់ថារដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស ក្រុមប្រឹក្សាឃុំ គឺកំពុងមានគណនេយ្យភាព និងឆ្លើយតបច្រើនឡើងចំពោះបញ្ហា/តម្រូវការរបស់ប្រជាពលរដ្ឋជាច្រើន។ អ្នកផ្ដល់ចម្លើយជាច្រើននាក់ដែលជាជនមានពិការភាព (PWDs) បានបញ្ចេញមតិថា ប្រហែលជា៧០% នៃអគារសាធារណៈ ដូចជា សាលារៀន និងមណ្ឌលសុខភាពជាច្រើនក្នុងស្រុកត្រាំកក់ (ខេត្តតាកែវ) បានបង្កើតលទ្ធភាពចូលបានល្អប្រសើរជាងមុនសម្រាប់ជនមានពិការភាព (PWDs)។ លើសពីនោះទៅទៀត ជនមានពិការភាព៧០% បានទទួលការគាំទ្រជាសម្ភារ/ឧបករណ៍ពីរដ្ឋាភិបាល។

## គោលបំណង/លទ្ធផលយុទ្ធសាស្ត្រទី២៖ ការចូលរួមរបស់ប្រជាពលរដ្ឋ

ការពិនិត្យមើលឯកសារ និងការអង្កេតតាមអនឡាញបានកំណត់កម្រិតនៃការពេញចិត្ត (របស់ប្រជាពលរដ្ឋនានាលើការបំពេញការងាររបស់រដ្ឋាភិបាល) ចំនួនព្រឹត្តិការណ៍ជាច្រើនដែលដឹកនាំ/ចូលរួមដោយអង្គការសហគមន៍ (ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈ និងទទួលខុសត្រូវចំពោះការសម្រេចចិត្ត និងសកម្មភាពរបស់ពួកគេ) និងកម្រិតនៃការពាក់ព័ន្ធរបស់ប្រជាពលរដ្ឋក្នុងការត្រួតពិនិត្យការសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលជាច្រើនគឺមានសង្ខេបនៅក្នុងតារាង៥ខាងក្រោម៖





# របាយការណ៍បីឆ្នាំ ២០១៩-២១

តារាង២៖ សង្ខេបលទ្ធផលនៃលទ្ធផលទី២៖ ការចូលរួមរបស់ប្រជាពលរដ្ឋ

| លទ្ធផលទី២៖ លើកស្ទួយសិទ្ធិអំណាចប្រជាពលរដ្ឋ ជាពិសេស យុវជន ស្ត្រី និងក្រុមងាយរងគ្រោះនានា ដើម្បីជំរុញឱ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះការសម្រេចចិត្ត និងសកម្មភាពនានាប្រកបដោយការឆ្លើយតប និងបរិយាបន្ន ដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈ និងការអនុវត្តគោលនយោបាយ (នៅកម្រិតក្រោមជាតិ)។ | |
|---|---|
| **សូចនាករនានាសម្រាប់វាស់វែងលទ្ធផលទី២៖** | **សង្ខេបលទ្ធផលធៀបនឹងសូចនាករ (២០១៩-២០២១)** |
| • ភាគរយប្រជាពលរដ្ឋ (បែងចែកតាមភេទ និងក្រុមងាយរងគ្រោះ) ការពេញចិត្តចំពោះការបំពេញការងាររបស់រដ្ឋាភិបាល។ | • របាយការណ៍ស្តីពីការសិក្សាដើមគ្រា[10] បានបញ្ជាក់ថា ៣៨,៨%នៃអ្នកផ្តល់ចម្លើយគឺពេញចិត្តចំពោះការបំពេញការងាររបស់រដ្ឋបាល និងក្រុមប្រឹក្សាមូលដ្ឋាន ក្នុងការផ្តល់សេវាសាធារណៈដែលទុកចិត្តបាន និងការឆ្លើយតបចំពោះតម្រូវការរបស់ពួកគេ។<br>• ការអង្កេតតាមអនឡាញ[11] បានបង្ហាញថាមានអ្នកឆ្លើយតប ៨០% បានប៉ាន់ប្រមាណថា "ល្អប្រសើរ" លើគុណភាពនៃការបំពេញការងារ/សេវាផ្សេងៗ។ |
| • ចំនួនព្រឹត្តិការណ៍/កិច្ចផ្តួចផ្តើមរួមគ្នានានាដែលដឹកនាំ ឬចូលរួមដោយអង្គការសហគមន៍ ក្រុមសាមគ្គី និងបណ្តាញយុវជន ស្ត្រី និងក្រុមងាយរងគ្រោះដែលផ្តោតលើការទាមទារ គណនេយ្យភាព ឆ្លើយតប ការសម្រេចចិត្ត និង សកម្មភាព ប្រកបដោយបរិយាបន្នដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវា សាធារណៈ និងការអនុវត្តគោលនយោបាយនៅកម្រិតក្រោមជាតិ។ | • អង្គការសហគមន៍ចំនួន១៦៩ (ក្នុងចំណោម១៧០) បានបង្កើត និងអនុវត្តផែនការតស៊ូមតិជាច្រើន។<br>• មានគម្រោងខ្នាតតូចចំនួន៥០[12] ត្រូវបានអនុវត្តដោយសមាជិកជាច្រើននៃសមាគមក្រុមប្រឹក្សាមូលដ្ឋានខេត្ត implemented (PALC) ដើម្បីដោះស្រាយបញ្ហា/តម្រូវការរបស់អ្នកក្រីក្រ និងក្រុមងាយរងគ្រោះបំផុត។ |
| • ចំនួននៃការសម្រេចចិត្ត និងសកម្មភាពនៃស្ថាប័នដែលផ្តល់សេវាសាធារណៈនានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រួតពិនិត្យដោយប្រជាពលរដ្ឋច្រើននាក់ដែលពិចារណាដល់តម្រូវការ និងអាទិភាពផ្សេងៗនៃសហគមន៍នានា ជាពិសេសស្ត្រី និងយុវជន និងក្រុមងាយរងគ្រោះ។ | • តាមរយៈការអង្កេតតាមអនឡាញមួយក្រុមប្រឹក្សា៩៦%[13] បានបញ្ចេញយោបល់ថាអង្គការសហគមន៍ជាច្រើនត្រូវបានអញ្ជើញឱ្យពាក់ព័ន្ធក្នុងសកម្មភាពត្រួតពិនិត្យនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និង៨៥%បាននិយាយថា ប្រជាពលរដ្ឋជាច្រើននាក់ (អ្នកតំណាងជាច្រើននាក់) ត្រូវបានផ្តល់ឱកាសដើម្បីលើកបញ្ហា/យោបល់ផ្សេងៗក្នុងអំឡុងពេលកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ មានអ្នកតំណាងអង្គការសហគមន៍៨១% បានបញ្ជាក់ច្បាស់ថាពួកគេធ្លាប់ត្រួតពិនិត្យ សកម្មភាពផ្សេងៗដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ |

របាយការណ៍ស្តីពីការសិក្សាដើមគ្រា[14] បានបង្ហាញថា ៣៨,៨% នៃអ្នកផ្តល់ចម្លើយដែលបែងចែកតាមភេទ និងក្រុមងាយរងគ្រោះ (ដែលនៅក្នុងនោះជនមានពិការភាពមាន២៥,០% យុវជនមាន៤០,៣% អ្នកកាន់ប័ណ្ណក្រីក្រមាន៣១,៣% និងស្ត្រីមាន ៣៥,៩%) គឺពេញចិត្តចំពោះការបំពេញការងារជាច្រើនរបស់រដ្ឋបាល និងក្រុមប្រឹក្សាមូលដ្ឋាន ក្នុងការផ្តល់សាវាសាធារណៈដែលលឿន និងទុកចិត្តច្រើនជាងមុន និងឆ្លើយតបទៅនឹងតម្រូវការនានារបស់ពួកគេ។

# របាយការណ៍បីឆ្នាំ ២០១៩-២១

តាមរយៈការអង្កេតតាមអនឡាញ[15] អ្នកផ្តល់ចម្លើយជាច្រើននាក់ត្រូវបានសុំឱ្យប៉ាន់ប្រមាណកម្រិតនៃភាពប្រសើរឡើងនៃការបំពេញការងាររបស់ស្រុក/ក្រុង/ខណ្ឌរវាងឆ្នាំ២០១៩ និងឆ្នាំ២០២១។ ៨០%នៃពួកគេបានប៉ាន់ប្រមាណថា "មានភាពប្រសើរឡើង" លើគុណភាពនៃការបំពេញការងារ/សេវានានា (ទទួលពិន្ទុចន្លោះពី៣ទៅ៥) ១១%បានប៉ាន់ប្រមាណថា "មានភាពប្រសើរឡើងខ្លាំងណាស់ (ពិន្ទុ៥)" ៣៤%បានប៉ាន់ប្រមាណថា "មានភាពប្រសើរឡើងខ្ពស់ (ពិន្ទុ៤)" និង ៣៥%បានប៉ាន់ប្រមាណថា "មានភាពប្រសើរឡើងល្មម (ពិន្ទុ៣)"។

ការពិនិត្យមើលឯកសារបានរកឃើញថាមានអង្គការសហគមន៍សរុបចំនួន១៦៩ (ក្នុងចំណោម១៧០ដែលបានទទួលការកសាងសមត្ថភាពពី API) នោះ បានបង្កើត និងអនុវត្តផែនការ/សកម្មភាពតស៊ូមតិនៅចន្លោះឆ្នាំ២០១៩ និង២០២១។

- មានក្រុមជនមានពិការភាព១ក្រុម (ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ)៖ បានធ្វើការអង្កេតសួរតគ្នា (snowball survey) និងប័ណ្ណពិន្ទុ និងបានប្រើលទ្ធផលនានានៃការអង្កេត/ប័ណ្ណពិន្ទុដើម្បីតស៊ូមតិជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពចូលប្រើប្រាស់ (accessibility) (សេវាសាធារណៈ ដូចជា សាលារៀន/មណ្ឌលសុខភាព) ជីវភាព និងកិច្ចគាំពារសង្គមសម្រាប់ជនមានពិការភាព។
- មានក្រុមទូតសុឆន្ទៈយុវជនចំនួន៨ក្រុម៖ បានធ្វើប័ណ្ណពិន្ទុដើម្បីតស៊ូមតិឱ្យសេវាផ្សេងៗរបស់ច្រកចេញចូលតែមួយ (OWSO) មានភាពប្រសើរឡើង (នៅស្រុកចំនួន៥ ក្នុងខេត្តបាត់ដំបង ក្រុងចំនួន១នៅខេត្តកំពង់ឆ្នាំង និងក្រុងចំនួន២នៅខេត្តបន្ទាយមានជ័យ)។
- មានក្រុមយុវជនចំនួន៤៖ បានតស៊ូមតិជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ (ស្រុកចំនួន៤នៅខេត្តកណ្តាល ក្រចេះ និងភ្នំពេញ) លើបញ្ហាជាច្រើនដែលទាក់ទងនឹងថ្នាំញៀន ក្មេងមិនចូលសាលារៀន ជំងឺកូវីដ-១៩ ការគ្រប់គ្រងសំណល់ សុវត្ថិភាពភូមិ ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននានា។
- មានអង្គការសហគមន៍ចំនួន៣៣ (មានសមាជិកចំនួន៩០នាក់ជាស្ត្រីជនជាតិដើមភាគតិច) បានតស៊ូមតិលើបញ្ហាដែលទាក់ទងនឹងការបំផ្លាញព្រៃឈើ និងការទន្ទ្រានយកទ្រព្យសម្បត្តិឯកជន (១៥ករណី) ការគាំទ្រហិរញ្ញវត្ថុ និងសម្ភារដល់សហគមន៍ដើម្បីល្បាតព្រៃ (១៥ករណី) ការផ្គត់ផ្គង់ទឹក និងការបណ្តុះបណ្តាលបច្ចេកទេសសម្រាប់ផលិតផលកសិកម្ម (៤ករណី) ការនេសាទខុសច្បាប់ និងការខ្វះការគាំទ្រហិរញ្ញវត្ថុ/សម្ភារសម្រាប់គាំទ្រសហគមន៍នេសាទក្នុងការល្បាតក្នុងតំបន់អភិរក្ស (២ករណី) កសាងឡើងវិញ និងថែទាំស្ពាន និងផ្លូវចាស់ៗ (២ករណី) និងតម្រូវការមានសាលាមតេយ្យនៅក្នុងសហគមន៍ (១ករណី)។[16]
- មានអង្គការសហគមន៍ចំនួន៨៥ (ធ្វើការលើបញ្ហាតាមវិស័យជាច្រើន) បានតស៊ូមតិជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិលើបញ្ហាដែលទាក់ទងនឹងសហគមន៍ព្រៃឈើ ការប្រើប្រាស់ដី ការបើកចំហថវិកា ការអប់រំ និងជីវភាពសហគមន៍។
- មានបណ្តាញយុវជនចំនួន១ បានតស៊ូមតិ (ជាមួយក្រសួងនានា និងសភា) ដើម្បីមានការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន (A2I)។
- មានក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ចំនួន១ក្រុម (ក្នុងខណ្ឌសែនសុខ) បានតស៊ូមតិឱ្យមានសេវាគាំពារសង្គមពីរដ្ឋាភិបាល (ដូចជា ថវិកាសន្តិសុខសង្គមជាតិ) និងឱ្យមានភាពប្រសើរឡើងនូវសេវាគាំពារសង្គមនៃសាលាបឋមសិក្សា មណ្ឌលសុខភាព និងសេវាឃុំ/សង្កាត់។
- មានក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ចំនួន៣៣ក្រុម (ក្នុងស្រុក/ក្រុងចំនួន៣៣) បានធ្វើផែនការតស៊ូមតិឱ្យមានភាពប្រសើរឡើងនូវសេវានៃសាលាបឋមសិក្សា មណ្ឌលសុខភាព និងសេវាឃុំ។
- មានក្រុមស្ត្រីអ្នកលក់ដូរតាមដងផ្លូវចំនួន៣ក្រុម (នៅភ្នំពេញ បាត់ដំបង និងសៀមរាប) បានតស៊ូមតិជាមួយខណ្ឌ/ក្រុងនានា និងអាជ្ញាធរផ្សារជាច្រើនដើម្បីលើកស្ទួយសិទ្ធិសេដ្ឋកិច្ចសង្គម កញ្ចប់គាំពារសង្គម (ដូចជា ប័ណ្ណសមធម៌ និងបេឡាជាតិរបបសន្តិសុខសង្គម (NSSF) និងទីកន្លែង/ទីតាំងតាមផ្សារនានាស្ត្រីអ្នកលក់តាមដងផ្លូវលក់ដូរ។

# របាយការណ៍បីឆ្នាំ ២០១៩-២១

ការពិនិត្យមើលឯកសារបានបង្ហាញថា មានគម្រោងខ្នាតតូចចំនួន៥០[17] (ដែលមានថវិកាសរុបចំនួន២១៣,២៥០ដុល្លារអាមេរិក) ត្រូវបានអនុវត្តដោយសមាជិកជាច្រើននៃសមាគមក្រុមប្រឹក្សាមូលដ្ឋានខេត្ត (PALC) ក្នុងខេត្តចំនួនប្រាំមួយ ដែលផ្តល់ថវិកាដោយ API ដើម្បីដោះស្រាយបញ្ហា និងតម្រូវការអាទិភាពនានារបស់អ្នកក្រីក្រ និងក្រុមងាយរងគ្រោះ (សរុបមានចំនួន១,០២៧គ្រួសារ ដោយរួមទាំង យុវជនចំនួន៤៣៥នាក់) ដែលប៉ះពាល់ផ្ទាល់ឬដោយប្រយោលពីការរីករាលដាលនៃជំងឺកូវីដ-១៩។

តាមរយៈការអង្កេតតាមអនឡាញ[18] មានអ្នកផ្តល់ចម្លើយ៨៥% (ដែលជាក្រុមប្រឹក្សាស្រុក/ខណ្ឌជាច្រើននាក់) បាននិយាយថា ប្រជាពលរដ្ឋនានា (អ្នកតំណាងជាច្រើននាក់) ត្រូវបានផ្តល់ឱកាសមួយដើម្បីលើកបញ្ហា/យោបល់ផ្សេងៗក្នុងអំឡុងពេលនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ ក្នុងខណៈដែល ៩៦%នៃអ្នកផ្តល់ចម្លើយ (ដែលជាក្រុមប្រឹក្សាស្រុក/ខណ្ឌជាច្រើននាក់) បានបញ្ចេញយោបល់ថា អង្គការសហគមន៍ត្រូវបានដាក់ឱ្យពាក់ព័ន្ធក្នុងសកម្មភាពត្រួតពិនិត្យនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយមានអ្នកផ្តល់ចម្លើយ៨១% (ដែលជាតំណាងអង្គការសហគមន៍ជាច្រើននាក់) បានបញ្ជាក់ច្បាស់ថា ពួកគេធ្លាប់ពាក់ព័ន្ធក្នុងសកម្មភាពត្រួតពិនិត្យដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងអំឡុងពេលនៃការពិភាក្សាក្រុមចំណាប់អារម្មណ៍ (FGDs) អ្នកផ្តល់ចម្លើយទាំងអស់ដែលជាតំណាងអង្គការសហគមន៍នោះ បានបញ្ជាក់ច្បាស់ថាពួកគេធ្លាប់ពាក់ព័ន្ធក្នុងសកម្មភាពត្រួតពិនិត្យទាំងឡាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា ការកសាងផ្លូវមូលដ្ឋាន និងសេវាសាលាបឋមសិក្សា/មណ្ឌលសុខភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ជនមានពិការភាព)។

ក្នុងអំឡុងពេលនៃការពិភាក្សាក្រុមចំណាប់អារម្មណ៍ និងសម្ភាសន៍ជនបង្គោល អ្នកផ្តល់ចម្លើយជាច្រើននាក់ (ដែលជាតំណាង NGOs/CBOs) បានបញ្ចេញយោបល់ថា អង្គការសហគមន៍/ក្រុមផ្សេងៗដែលមានរបៀបវារៈជាក់លាក់សម្រាប់ការតស៊ូមតិ (ដូចជា ការនេសាទខុសច្បាប់ ការបំផ្លាញព្រៃឈើ និងបញ្ហាដីធ្លី) និងធ្វើការនៅក្នុងរចនាសម្ព័ន្ធល្អជាច្រើន (ដូចជា NRM) ត្រូវដាក់ឱ្យចូលពាក់ព័ន្ធយ៉ាងសកម្មជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ពួកគេបានរៀបចំខ្លួនជាស្រេចបានល្អក្នុងការចូលរួមក្នុងប្រជុំឃុំ/សង្កាត់។ ជាធម្មតា ពួកគេបានរៀបចំប្រជុំផ្ទៃក្នុងដើម្បីកំណត់ការរីកចម្រើន និងកត្តាប្រឈមផ្សេងៗនៃប្រតិបត្តិការកំពុងដំណើរការរបស់ពួកគេ និងកំណត់ជំហររបស់ខ្លួនសម្រាប់ការពិភាក្សាបន្តទៅមុខទៀតជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ ឬ/និងក្រុមប្រឹក្សាស្រុក។ ឧទាហរណ៍ សហគមន៍នេសាទនៅព្រែកហ្លួងក្នុងខេត្តបាត់ដំបងបានធ្វើការជាមួយបណ្តាញជាច្រើនក្នុងខេត្តជិតខាងនានាដើម្បីរួមគ្នាលើកបញ្ហាផ្សេងៗអំពីការនេសាទខុសច្បាប់ ដើម្បីឱ្យមានការយកចិត្តទុកដាក់ពីអាជ្ញាធររបស់អភិបាលខេត្ត។ ការពិភាក្សាជាច្រើនត្រូវបានធ្វើឡើងជាមួយសង្កាត់ជលផល ហើយសង្កាត់បានផ្តល់ការគាំទ្រដ៏មានប្រយោជន៍ដែលដាក់ចេញដោយប្រជុំខេត្ត។ ជាលទ្ធផល សកម្មភាពខុសច្បាប់ជាច្រើនត្រូវបានថយចុះយ៉ាងខ្លាំង។ ឃុំជាច្រើននៅជុំវិញតំបន់អភិរក្សនេសាទបានចាត់តាំងក្រុមប្រឹក្សាជាច្រើននាក់ឱ្យធ្វើការជិតដិតជាមួយសហគមន៍នេសាទ និងអង្គការសហគមន៍ដទៃទៀតជាច្រើនសម្រាប់តាមដាន និងដោះស្រាយសកម្មភាពនេសាទខុសច្បាប់ទាំងឡាយ។

ក្នុងអំឡុងពេលនៃការពិភាក្សាក្រុមចំណាប់អារម្មណ៍ (FGDs) អ្នកផ្តល់ចម្លើយដែលជាអង្គការសហគមន៍ភាគច្រើនបំផុត (រួមទាំងក្រុមជនមានពិការភាព (PWD) NRM ជនជាតិដើមភាគតិច (IP) ក្រុមយុវជន) បានបញ្ចេញយោបល់ថា ឃុំ/សង្កាត់ភាគច្រើនបំផុតនៅក្នុងតំបន់គោលដៅរបស់ពួកគេទទួលស្គាល់តួនាទីសំខាន់ៗនៃប្រជាពលរដ្ឋ ជាពិសេសក្រុមជនងាយរងគ្រោះបំផុត ក្រុមស្ត្រី និងយុវជនជាច្រើនក្រុម ហើយពួកគេបានព្យាយាមវិធីដែលអាចទៅរួចទាំងអស់ដើម្បីឱ្យពួកគេពាក់ព័ន្ធ ជាពិសេសក្នុងប្រជុំប្រចាំខែ។ ក្រុមប្រឹក្សាឃុំ/សង្កាត់ភាគច្រើនបំផុតគឺបើកចំហឱ្យមានការចូលរួមច្រើន និងការរីកចម្រើន និងកត្តាប្រឈមនៅក្នុងឃុំ/សង្កាត់នានា (រួមទាំងការរៀបចំ និងការប្រើប្រាស់ថវិកា) គឺជានិច្ចកាល ត្រូវបានដាក់បញ្ចូលក្នុងរបៀបវារៈប្រជុំ។

# របាយការណ៍បីឆ្នាំ ២០១៩-២១

## គោលបំណង/លទ្ធផលយុទ្ធសាស្ត្រទី៣៖ ធ្វើឱ្យសិទ្ធិទទួលបានព័ត៌មានប្រសើរឡើង

ការពិនិត្យមើល និងការអង្កេតតាមអនឡាញបានបង្ហាញឱ្យឃើញនូវចំនួនសន្ទឹកសន្ធាប់មួយនៃប្រជាពលរដ្ឋដែលបានចូលរួមក្នុងវគ្គផ្សព្វផ្សាយការយល់ដឹងជាច្រើន ដែលរៀបចំដោយ API ប៉ាន់ប្រមាណ និងផ្តល់យោបល់ត្រឡប់លើព័ត៌មានសាធារណៈ និងចំនួនស្ថាប័នដែលបើកចំហព័ត៌មានដល់សាធារណជន។ លទ្ធផលគឺសង្ខេបនៅក្នុងតារាង៦ខាងក្រោម៖

**តារាង៣៖ សង្ខេបលទ្ធផលទី៣៖ ធ្វើឱ្យសិទ្ធិទទួលបានព័ត៌មានប្រសើរឡើង**

| លទ្ធផលទី៣៖ ធ្វើឱ្យប្រសើរឡើងនូវការបើកចំហព័ត៌មានសាធារណៈស្តីពីបញ្ហាសំខាន់ៗ | |
|---|---|
| **សូចនាករនានាសម្រាប់វាស់វែងលទ្ធផលទី៣៖** | **សង្ខេបលទ្ធផលធៀបនឹងសូចនាករ (២០១៩-២០២១)** |
| • ភាគរយនៃកម្រិតប្រជាពលរដ្ឋដែលបានកើនការយល់ដឹងអំពីសិទ្ធិទទួលបានព័ត៌មានសាធារណៈ និងអនុវត្តសិទ្ធិស្របច្បាប់របស់ពួកគេក្នុងការទាមទារ និងប្រើប្រាស់ព័ត៌មានសាធារណៈស្តីពីបញ្ហាសំខាន់ៗ សម្រាប់ការធ្វើឱ្យប្រសើរឡើងនូវការចូលរួម និងជីវភាពរបស់សាធារណជន។ | • មានប្រជាពលរដ្ឋចំនួន៤៨៥,១៤០នាក់[19] បានចូលរួមក្នុងការផ្សព្វផ្សាយការយល់ដឹងស្តីពីប្រធានបទខុសៗគ្នាដែលរៀបចំដោយ API។<br>• មានប្រជាពលរដ្ឋចំនួន៣១,៧១១នាក់ បានចូលប្រើប្រាស់ព័ត៌មានសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានផ្តល់យោបល់ត្រឡប់ជាច្រើនដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈនានា។ |
| • ចំនួនស្ថាប័នសាធារណៈនានានៅកម្រិតជាតិ និងថ្នាក់ក្រោមជាតិ ដែលតស៊ូមតិដោយសកម្មភាពគម្រោងបានធ្វើឱ្យកើនឡើងនូវការបើកចំហព័ត៌មានសាធារណៈស្តីពីបញ្ហាសំខាន់ៗសម្រាប់ធ្វើឱ្យមានតម្លាភាពខ្លាំងជាងមុន។ | • មានស្ថាប័នសាធារណៈចំនួន៦៧៨ បានបើកចំហព័ត៌មានអំពីចំណូលប្រចាំឆ្នាំ និងចំណាយរបស់វា សូមចូលមើល ISAF App & Citizen Budget App។<br>• តាមរយៈការអង្កេតតាមអនឡាញ[20] អ្នកផ្តល់ចម្លើយ៤៩% ធ្លាប់ចូលរួមក្នុងប្រជុំក្រុមប្រឹក្សាឃុំជាច្រើន និង៤៧%ធ្លាប់ចូលរួមក្នុងប្រជុំស្រុក/ក្រុង។ |





# របាយការណ៍បីឆ្នាំ ២០១៩-២១

លទ្ធផលជាច្រើនដែលបានពីការពិនិត្យមើលឯកសារបានបង្ហាញថា API បានធ្វើឱ្យមានការរីកចម្រើនធៀបនឹងសូចនាករនានាសម្រាប់លទ្ធផលទី៣នៃផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩ – ២០២៣។

ទីមួយ API បាន និងកំពុងអនុវត្តការផ្សព្វផ្សាយការយល់ដឹង ដែលពាក់ព័ន្ធនឹងចំនួនសន្ទឹកសន្ធាប់មួយនៃប្រជាពលរដ្ឋ រួមទាំង៖

- ស្ត្រី និងប្រជាជនមកពីក្រុមងាយរងគ្រោះចំនួន៥,០០០នាក់ បានកើនការយល់ដឹងអំពីសិទ្ធិប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានសាធារណៈ ដូចជា ការបង្កើត និងអនុវត្តថវិកាឃុំ និងផែនការវិនិយោគឃុំ (CIP)។
- មានប្រជាពលរដ្ឋចំនួន៤,០៥១នាក់ (ស្ត្រីចំនួន២,៦៧៥នាក់) នៅខេត្តកោះកុង ក្រចេះ រតនគិរី មណ្ឌលគិរី និងស្ទឹងត្រែង បានដឹងពីសិទ្ធិប្រជាពលរដ្ឋ ស្តង់ដារសេវាធារណៈ និងការបង្កើតថវិកា។
- មានប្រជាពលរដ្ឋចំនួន១៦៦,០៨៩នាក់ (ស្ត្រីចំនួន៨៦,៦០០នាក់) ក្នុងឃុំគោលដៅចំនួន១៥បានធ្វើឱ្យប្រសើរឡើងនូវសិទ្ធិទទួលបានព័ត៌មានរបស់ពួកគេ (អំពីព័ត៌មានជំងឺកូវីដ-១៩ ប្រចាំថ្ងៃ និងវិធានបង្ការ)។
- មានប្រជាជនចំនួន៣១០,០០០នាក់ បានទទួលការផ្សព្វផ្សាយពីប្រព័ន្ធផ្សព្វផ្សាយសង្គមស្តីពីគណនេយ្យភាពសង្គម និងសេវាសាធារណៈនានា។ ទាំងនេះមានរួមទាំងអ្នកប្រើប្រាស់ហ្វេសប៊ុកចំនួន៥៦,៧០៩នាក់ដែលចូលមើលខ្សែវីដេអូអប់រំខ្លីៗមួយស៊េរីអំពីសេវានានារបស់រដ្ឋបាលមូលដ្ឋាន និងអ្នកផ្តល់សេវាមូលដ្ឋាននានា។

ទីពីរ តាមរយៈអន្តរាគមន៍របស់ API ជាច្រើននោះ មានប្រជាពលរដ្ឋច្រើនសន្ធឹកសន្ធាប់បានចូលដល់ព័ត៌មាន និងបានផ្តល់យោបល់ត្រឡប់ជាច្រើនអំពីព័ត៌មានសាធារណៈ៖

- មានប្រជាពលរដ្ឋចំនួន១១,៥៥៣នាក់ (ស្ត្រី៣,៤៥៣នាក់) បានចូលដល់ព័ត៌មានថវិកាស្រុក។
- មានប្រជាពលរដ្ឋចំនួន១០,០០០នាក់បានចូលដល់/បានប៉ាន់ប្រមាណសេវាច្រកចេញចូលតែមួយ (ក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងកំពង់ឆ្នាំង) តាមរយៈ IVR និង Facebook_Chatbot។
- មានប្រជាជនចំនួន៧,២៧១នាក់ (ស្ត្រីចំនួន៤,៩២៣នាក់) ក្នុងឃុំ/សង្កាត់ចំនួន២៤ ដែលបានចូលផ្ទាល់ដល់ព័ត៌មានស្តីពីថវិកា និងស្តង់ដារសេវារបស់មណ្ឌលសុខភាព សាលាបឋមសិក្សា ឃុំ និងប៉ូលីសប៉ុស្តិ៍ជាច្រើន។
- មានប្រជាពលរដ្ឋចំនួន២,៨៨៧នាក់ (រួមទាំងជនមានពិការភាពចំនួន៤៦៤នាក់ ប្រជាជនចំនួន៤២៣នាក់ នៅភ្នំពេញ និង ២,០០០នាក់នៅខេត្តបាត់ដំបង បន្ទាយមានជ័យ និងកំពង់ធំ) បានផ្តល់យោបល់ត្រឡប់ជាច្រើនដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈ ទាំងស្តង់ដារសេវា និងនីតិវិធីព័ត៌មានរបស់វា។

ទីបី មានស្ថាប័នសាធារណៈចំនួន៦៧៨[21] ដែលបានបើកចំហព័ត៌មានអំពីថវិកា និងព័ត៌មាននៃស្តង់ដារសេវា។ ពួកគេត្រូវត្រួតពិនិត្យដោយតំណាងប្រជាពលរដ្ឋដែលបានបណ្តុះបណ្តាលត្រឹមត្រូវរបស់ API។ តាមរយៈការអង្កេតតាមអនឡាញ[22] ៤៩%នៃអ្នកផ្តល់ចម្លើយ (ដែលជាប្រជាពលរដ្ឋ យុវជន និងអ្នកតំណាងអង្គការសហគមន៍) បានបញ្ជាក់ថា ពួកគេបានចូលរួមក្នុងប្រជុំក្រុមប្រឹក្សាឃុំ និង៤៧%ធ្លាប់ចូលរួមប្រជុំស្រុក/ក្រុងជាច្រើន។ ៥២%បានបញ្ជាក់ច្បាស់ថា រដ្ឋបាលថ្នាក់ក្រោមជាតិបានបើកចំហព័ត៌មាន(អំពីថវិកា សេវានានា និងផែនការអភិវឌ្ឍន៍ឃុំ) នៅទីសាធារណៈ។

តាមរយៈសម្ភាសន៍ជនបង្គោល/ការពិភាក្សាក្រុមចំណាប់អារម្មណ៍ជាច្រើន អ្នកផ្តល់ចម្លើយទាំងអស់ (១០០%) បានបញ្ជាក់ច្បាស់ថា រដ្ឋបាលថ្នាក់ក្រោមជាតិបានបើកចំហព័ត៌មានដែលពួកគេស្រួលចែករំលែកនៅក្នុងទីសាធារណៈ ដូចជា ព័ត៌មានអំពីថវិកាឃុំនានា និងតម្លៃសេវាដែលផ្តល់ដោយឃុំ ប៉ូលីសប៉ុស្តិ៍ និងសាលារៀនជាដើម។ល។

# របាយការណ៍បីឆ្នាំ ២០១៩-២១

## គោលបំណង/លទ្ធផលយុទ្ធសាស្ត្រទី៤៖ ការអភិវឌ្ឍអង្គការរបស់ API

ការពិនិត្យមើលឯកសារ និងការអង្កេតតាមអនឡាញបានកំណត់ភាពប្រសើរឡើងដ៏អស្ចារ្យក្នុងសមត្ថភាព API។ លទ្ធផលត្រូវបានសង្ខេបក្នុងតារាង៧ខាងក្រោម៖

**តារាង៤៖ សង្ខេបលទ្ធផលទី៤៖ ការអភិវឌ្ឍអង្គការរបស់ API**

| លទ្ធផលទី៤៖ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពអង្គការ និងនិរន្តរភាពរបស់ API | |
|---|---|
| **សូចនាករនានាសម្រាប់វាស់វែងលទ្ធផលទី៤៖** | **សង្ខេបលទ្ធផលធៀបនឹងសូចនាករ (២០១៩-២០២១)** |
| • % នៃថវិកាអង្គការដែលបានធ្វើឱ្យមានភាពចម្រុះ និងកើនឡើងរៀងរាល់ឆ្នាំ។ | • មូលនិធិរបស់ API បានកើនឡើង៥៦%ក្នុងឆ្នាំ២០២០ និង២៨%ក្នុងឆ្នាំ២០២១។ |
| • % នៃធនធានមនុស្ស និងជំនាញផ្សេងៗដែលកើនឡើង និង % នៃកម្រិតដែលបានថយចុះនូវបុគ្គលិកដែលអស់កម្លាំងចិត្ត និងបុគ្គលិកលាឈប់។ | • បុគ្គលិក API កើនឡើងពី១៨នាក់ទៅ៣៤នាក់ (៨៩%) ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២១។<br>• API បន្តមានបុគ្គលិកលាឈប់ក្នុងកម្រិតខ្ពស់។ |
| ចំនួនប្រជុំទៀងទាត់របស់ថ្នាក់គ្រប់គ្រងអង្គការ (ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង) យោបល់ត្រឡប់ ដើម្បីរៀនសូត្រជាមួយអ្នកពាក់ព័ន្ធជាច្រើនដើម្បីធ្វើឱ្យប្រសើរឡើងនូវគម្រោង និងគណនេយ្យភាព តម្លាភាព ការលូតលាស់ និងនិរន្តរភាពអង្គការ។ | • API ត្រូវបានផ្តល់រង្វាន់ជាវិញ្ញាបនបត្រ GPP នៅឆ្នាំ ២០១៩។<br>• API គឺគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល BoD។ សមាជិកជាច្រើននាក់នៃក្រុមប្រឹក្សាភិបាលមានជំនាញចម្រុះ/ពាក់ព័ន្ធសម្រាប់គាំទ្រ API។<br>• ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងរបស់ API បានធ្វើកិច្ចប្រជុំទៀងទាត់ជាច្រើនស្របតាមលក្ខន្តិកៈ និងគោលនយោបាយនានា។ |
| ប្រព័ន្ធតាមអនឡាញសម្រាប់ការធ្វើផែនការ និងការត្រួតពិនិត្យ ការវាយតម្លៃ គណនេយ្យភាព និងការរៀនសូត្រ (MEAL) ត្រូវបានបង្កើតឡើង និងអនុវត្តសម្រាប់គ្រប់គម្រោងទាំងអស់។ | • ក្នុងឆ្នាំ២០២១ API បានធ្វើឱ្យ MEAL template របស់ខ្លួនមានស្តង់ដារ និងកំពុងដំណើរការបង្កើតប្រព័ន្ធទិន្នន័យ MEALតាមអនឡាញ។ |

ក្រុមវាយតម្លៃបានប៉ាន់ប្រមាញផ្នែកគន្លឹះៗចំនួនប្រាំដើម្បីវាស់វែងការរីកចម្រើនដែលបានធ្វើឡើងធៀបនឹងលទ្ធផលយុទ្ធសាស្ត្រទី៤នៃការអភិវឌ្ឍអង្គការរបស់ API។ ផ្នែកគន្លឹះៗទាំងនោះ រួមមានអភិបាលកិច្ច និងភាពជាអ្នកដឹកនាំ គោលនយោបាយអង្គការនានា រចនាសម្ព័ន្ធប្រតិបត្តិ និងការគ្រប់គ្រងបុគ្គលិក គោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យ និងវាយតម្លៃ (M&E guidelines) និងការកៀរគរធនធានផ្សេងៗ។

# របាយការណ៍បីឆ្នាំ ២០១៩-២១

## អភិបាលកិច្ច និងភាពជាអ្នកដឹកនាំ

API គឺគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលមួយដែលមានសមាជិកចំនួន៥នាក់ (រួមទាំងស្ត្រីចំនួន២នាក់)។ ផ្អែកលើលក្ខន្តិកៈ ក្រុមប្រឹក្សាភិបាលជួបប្រជុំពីរដងក្នុងមួយឆ្នាំដើម្បីពិនិត្យមើលការរីកចម្រើន និងមុខងារនៃអង្គការ ក៏ដូចជាធ្វើការសម្រេចចិត្តសំខាន់ៗលើគោលនយោបាយ និងការផ្លាស់ប្តូរនៅក្នុងអង្គការ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងភាពពិត ក្រុមប្រឹក្សាភិបាលរបស់ API បានធ្វើកិច្ចប្រជុំវិសាមញ្ញជាច្រើនដើម្បីដោះស្រាយបញ្ហាអង្គការបន្ទាន់ៗ បន្ថែមពីលើការប្រជុំធម្មតាដែលកំណត់នៅក្នុងលក្ខន្តិកៈ។

ជាទូទៅ សមាជិកក្រុមប្រឹក្សាភិបាលគឺសកម្មក្នុងការផ្តល់ការគាំទ្រ និងលើកសំណួរសំខាន់ៗជាច្រើនដល់ API។ សមាជិកក្រុមប្រឹក្សាភិបាលជាច្រើននាក់មានជំនាញ និងបទពិសោធន៍ចម្រុះ រួមទាំងហិរញ្ញវត្ថុ ការរកមូលនិធិ ការគ្រប់គ្រងកម្មវិធី និងការបញ្ច្រៀបយេនឌ័រ។ ក្រុមប្រឹក្សាភិបាលបានដើរតួនាទីសំខាន់ជាច្រើនក្នុងការណែនាំ API ដល់ម្ចាស់ជំនួយ/ទីភ្នាក់ងារផ្តល់មូលនិធិជាច្រើន។ ប្រធានក្រុមប្រឹក្សាភិបាលគឺសកម្មណាស់ក្នុងការផ្តល់ជំនួយបច្ចេកទេសដល់នាយកប្រតិបត្តិ និងអង្គភាពហិរញ្ញវត្ថុ ដូចជា ការឆ្លើយតបទៅនឹងបញ្ហាសារវនកម្មជាច្រើន។

នាយកប្រតិបត្តិរបស់ API គឺសកម្មខ្លាំងណាស់ក្នុងពាក់ព័ន្ធជាមួយបណ្តាញដ៏ទូលំទូលាយ និងមានជំនាញប្រាស្រ័យទាក់ទង និងជំនាញអន្តរបុគ្គលយ៉ាងល្អប្រសើរ។ ជំនាញអ្នកដឹកនាំរបស់គាត់លូតលាស់បានយ៉ាងល្អ ដូចបានបង្ហាញក្នុងសមត្ថភាពគ្រប់គ្រងការលូតលាស់របស់ API នៅក្នុងរយៈពេលពីរ បី ឆ្នាំនៃការដឹកនាំរបស់គាត់។

សមត្ថភាពធំធេងរបស់ API ក្នុងការរកមូលនិធិ ជាពិសេស ការថែទាំទំនាក់ទំនងយូរអង្វែងជាមួយម្ចាស់ជំនួយនានា ដូចជា BfdW/DCA បានឆ្លុះបញ្ចាំងឱ្យឃើញពីអភិបាលកិច្ច និងការដឹកនាំរឹងមាំ។ ប្រការនេះបានបញ្ជាក់ច្បាស់ដោយក្រុមប្រឹក្សាភិបាល និងម្ចាស់ជំនួយ/អ្នកផ្តល់មូលនិធិគន្លឹះៗរបស់ API។[23] API ត្រូវបានប្រគល់រង្វាន់ជាវិញ្ញាបនបត្រនៃការអនុវត្តតាមត្រឹមត្រូវទៅនឹងអភិបាលកិច្ច និងការអនុវត្តជាវិជ្ជាជីវៈ (២០១៩)។

## គោលនយោបាយអង្គការនានា

API មានគោលនយោយបាយប្រតិបត្តិគ្រឹះ និងយន្តការរឹងមាំជាច្រើនដើម្បីនាំផ្លូវការអនុវត្តយុទ្ធសាស្ត្របច្ចុប្បន្ន។ គោលនយោបាយគន្លឹះៗរបស់អង្គការ រួមមានលក្ខន្តិកៈ សៀវភៅក្បួនស្តីពីក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង យន្តការបណ្តឹងតវ៉ា គោលនយោបាយបុគ្គលិក គោលការណ៍ណែនាំ/សៀវភៅក្បួនខាងហិរញ្ញវត្ថុ គោលការណ៍ណែនាំអំពីការត្រួតពិនិត្យ និងវាយតម្លៃ គោលនយោបាយប្រឆាំងអំពើពុករលួយ គោលនយោបាយស្តីពីទំនាស់ផលប្រយោជន៍ និងគោលនយោបាយការពារ/គាំពារកុមារ។ API អនុវត្តតាមបទបញ្ញត្តិរដ្ឋាភិបាលទាំងអស់ដែលពាក់ព័ន្ធ។

ទីប្រឹក្សារបស់ API (ជាសមាជិកម្នាក់នៃគណៈគ្រប់គ្រង) បានបញ្ជាក់ច្បាស់ តាមរយៈអ៊ីមែលរបស់គាត់ថា គោលការណ៍ណែនាំអំពីហិរញ្ញវត្ថុ/នីតិវិធីគណនេយ្យ និងសៀវភៅក្បួនអំពីបុគ្គលិកគឺស្ថិតក្នុងការពិនិត្យ ហើយរំពឹងថានឹងត្រូវបានបញ្ចប់ និងអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ API នៅខែកុម្ភៈ ឆ្នាំ២០២២។ ស្រដៀងគ្នានេះដែរ គោលនយោបាយអំពី IT/ICT គឺកំពុងព្រាងហើយរំពឹងថានឹងបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅខែកុម្ភៈ ឆ្នាំ២០២២ដែរ។

# របាយការណ៍បីឆ្នាំ ២០១៩-២១

## រចនាសម្ព័ន្ធ និងការគ្រប់គ្រងបុគ្គលិក

API បានធំលូតលាស់ជាអង្គការធំមួយចាប់តាំងពីឆ្នាំ២០២០ (ស្ទើរតែមានទំហំទ្វេដង ប្រសិនបើធៀបនឹងឆ្នាំ២០១៩)។ API មានការិយាល័យធំនៅរាជធានីភ្នំពេញ ហើយអនុវត្តគម្រោងជាច្រើននៅទូទាំងប្រទេស។ ក្នុងគម្រោងពីរ បី បុគ្គលិក API បាន និងកំពុងអាចចែករំលែក/ប្រើការិយាល័យរបស់ដៃគូជាច្រើនសម្រាប់ការងារប្រចាំថ្ងៃរបស់ពួកគេនៅតាមតំបន់គោលដៅ។ API មានកម្មវិធីចម្រុះច្រើនប្រភេទ បុគ្គលិកតំបន់គោលដៅ និងអ្នកទទួលផលគោលដៅជាច្រើន។ អស់ពេលរយៈពេល៣ឆ្នាំ (២០១៩ – ២០២១) មកហើយដែលបុគ្គលិក API បានកើនពី១៨នាក់ទៅ៣៤នាក់ (រួមទាំងស្ត្រីចំនួន១៤នាក់)។ បន្ថែមពីលើនេះទៀត API បានផ្តល់ការងារធ្វើដល់បុគ្គលិកពាក់កណ្តាលម៉ោងចំនួន២នាក់ (ប្រុសទាំងអស់) និងអ្នកស្ម័គ្រចិត្តចំនួន៦នាក់ (ស្ត្រីចំនួន៣នាក់)។

ជាទូទៅ បុគ្គលិក API ចូលចិត្តបរិយាកាសការងារនៅក្នុងអង្គការ API និងសម្ព័ន្ធមេត្រីភាពរវាងបុគ្គលិកផងដែរ។ ពួកគេមានអារម្មណ៍ថា ពួកគេទទួលបានឱកាសច្រើនសម្រាប់អភិវឌ្ឍសមត្ថភាពតាមរយៈការងាររបស់ពួកគេ រៀនសូត្រដោយការធ្វើផ្ទាល់ ឬការអនុវត្តក្នុងការងារបន្ថែមលើការបណ្តុះបណ្តាល/កម្មវិធីកសាងសមត្ថភាពនៅក្នុង និងក្រៅអង្គការដែលផ្តល់ឱ្យដោយ API។ API បានរៀបចំការឆ្លុះបញ្ចាំងអំពីបុគ្គលិកប្រចាំឆ្នាំទៀងទាត់នៅចុងឆ្នាំនីមួយៗ។ ក្នុងការឆ្លុះបញ្ចាំង បុគ្គលិកទាំងអស់មកជួបជុំគ្នាដើម្បីពិនិត្យមើលការរីកចម្រើន និងការសម្រេចបានប្រចាំឆ្នាំ ឆ្លុះបញ្ចាំងពីកត្តាប្រឈមផ្សេងៗ និងវិធីយកឈ្នះ ទាញជាមេរៀន និងផែនការសម្រាប់ឆ្នាំបន្ទាប់។ API ធ្វើការវាយតម្លៃបុគ្គលិកម្តងក្នុងមួយឆ្នាំ សម្រាប់បុគ្គលិកទាំងអស់កែលម្អការបំពេញការងាររបស់ពួកគេ។ បុគ្គលិក API ត្រូវបានផ្តល់ឱកាសផងដែរដើម្បីចូលរួមក្នុងប្រជុំជាច្រើន ដូចជា ប្រជុំបណ្តាញ/ដៃគូនានា ដែលទាក់ទងនឹងការងារ/មុខតំណែងរបស់ពួកគេ។

## គោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យ និងវាយតម្លៃ

API មានគោលការណ៍ណែនាំស្តីពីការត្រួតពិត្យ និងវាយតម្លៃមួយសម្រាប់ប្រើក្នុងការតាមដាន/ប្រមូលផ្តុំទិន្នន័យសម្រាប់ការរាយការណ៍ (ទៅអ្នកពាក់ព័ន្ធខុសៗគ្នាជាច្រើន) និងការពង្រឹងការរៀនសូត្រផ្ទៃក្នុង។ ចំពោះកម្រិតគម្រោងវិញ API បានធ្វើការងារសមរម្យមួយក្នុងការអភិវឌ្ឍឧបករណ៍ជាច្រើនដើម្បីប្រមូលទិន្នន័យប្រកបដោយគុណភាពល្អល្មម ដែលហៅថា ទម្រង់ត្រួតពិនិត្យវាយតម្លៃ គណនេយ្យភាព និងរៀនសូត្រ ((MEAL) Templates) របស់ API។ API បានធ្វើកិច្ចប្រជុំទៀងទាត់ជាច្រើន (ប្រជុំបុគ្គលិក ប្រជុំគណៈគ្រប់គ្រង និងប្រជុំដៃគូ) និងការឆ្លុះបញ្ចាំងអំពីគម្រោងដើម្បីតាមដានការរីកចម្រើននៃបទអន្តរាគមន៍នៃគម្រោងរបស់វា។

នៅឆ្នាំនេះ (២០២១) ដោយមានការគាំទ្រពីមន្ត្រីជំនាញត្រួតពិនិត្យ និងវាយតម្លៃ (MEAL specialist) API បានធ្វើឱ្យមានស្តង់ដារនូវទម្រង់ត្រួតពិនិត្យវាយតម្លៃ (MEAL template) របស់ខ្លួន (ទម្រង់ Excel) និងកំពុងស្ថិតក្នុងដំណើរការអភិវឌ្ឍន៍ប្រព័ន្ធទិន្នន័យតាមអនឡាញ (MEAL online database)។

## ការកៀរគរធនធាន (ដើម្បីគាំទ្រកម្មវិធី និងប្រតិបត្តិការអង្គការ)

API បានបង្កើតយុទ្ធសាស្ត្រនៃការរកមូលនិធិមួយដើម្បីនាំផ្លូវក្នុងការរកម្ចាស់ជំនួយ/អ្នកផ្តលមូលនិធិច្រើនប្រភេទដើម្បីគាំទ្រគម្រោង/មូលនិធិស្នូលសម្រាប់អង្គការ និងដើម្បីចៀសវាងការពឹងផ្អែកលើម្ចាស់ជំនួយ/អ្នកផ្តល់មូលនិធិមួយ ឬពីរប៉ុណ្ណោះ។ យុទ្ធសាស្ត្រនៃការរុករកមូលនិធិកំណត់ផងដែរនូវម្ចាស់ជំនួយ/អ្នកផ្តល់មូលនិធិសក្តានុពលជាច្រើនដើម្បីសំដៅទៅរកម្ចាស់ជំនួយ/អ្នកផ្តល់មូលនិធិទាំងនោះសម្រាប់សហប្រតិបត្តិការ។

# របាយការណ៍បីឆ្នាំ ២០១៩-២១

ដើម្បីធានាឱ្យការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព និងសុក្រិត API បានចុះកិច្ចសន្យាជួលក្រុមហ៊ុនខាងក្រៅជាច្រើនដែលមានគុណវុឌ្ឍិដើម្បីធ្វើសវនកម្មហិរញ្ញវត្ថុជាប្រចាំ (ទាំងគម្រោង និងសវនកម្មទូទៅ) និងបានសហការណ៍ជាមួយម្ចាស់ជំនួយ/អ្នកផ្តល់មូលនិធិគន្លឹះជាច្រើនដើម្បីប៉ាន់ប្រមាណប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គការ។

លទ្ធផលនៃការពិនិត្យឯកសារបានបញ្ជាក់អំពីការកើនឡើងយ៉ាងលឿននៃមូលនិធិពីមួយឆ្នាំទៅមួយឆ្នាំ។

តារាង៥៖ របាយការណ៍ហិរញ្ញវត្ថុរបស់ API ឆ្នាំ២០១៩ – ២០២១

| **បរិយាយ** | **បរិមាណជាដុល្លារអាមេរិក** (USD) | | |
|---|---|---|---|
| | **២០១៩** | **២០២០** | **២០២១ (ប្រហាក់ប្រហែល)** |
| ចំណូល | ៧៣២,១៦៥ | ១,១៤២,០៤៨ | ១,៤៥៨,៤៨០ |
| ចំណាយ | ៥១០,៣២២ | ៨១៣,២៣៥ | ១,០៣៤,៣៦៨ (ត្រឹមខែធ្នូ ២០២១) |
| តុល្យភាព | ២២១,៨៤៣ | ៣២៨,៨១៣ | ៤៤០,៧៥៩ |
| **% ចំណូលប្រចាំឆ្នាំកើនឡើង** | | ១៥៦% | ១២៨% |





# របាយការណ៍បីឆ្នាំ ២០១៩-២១

## មេរៀនសំខាន់ៗដែលបានរៀនសូត្រ

វាគឺអាចធ្វើទៅកើត ក្នុងការទាញយកមេរៀនមួយចំនួនពីការងាររបស់ API ក្នុងរយៈពេលពីឆ្នាំ២០១៩ ដល់ ឆ្នាំ២០២១។ មេរៀនជាច្រើនត្រូវបានដាក់បញ្ចូលនៅក្នុងរបកគំហើញដែលបានបង្ហាញនៅខាងលើ។ ប៉ុន្តែ ផ្នែកនេះនៃរបាយការណ៍គឺនាំមកនូវការវាយតម្លៃដែលក្រុមបានរកឃើញជាមេរៀននានា។

### ការធ្វើការជាមួយអង្គការសហគមន៍ជាច្រើនដែលមានស្រាប់

ថ្វីបើអង្គការសហគមន៍បាន និងកំពុងកើតឡើងតាមបែបប្រពៃណីនោះ ទាក់ទងនឹងប្រភពដើមនៃសង្គមវប្បធម៌ និងសង្គមសាសនាជាច្រើននៅក្នុងប្រទេសកម្ពុជា ដូចជា ក្រុមដោះដូរចាន និងឆ្នាំង សមាគមបុណ្យសព និងគណៈកម្មការវត្ត អង្គការសហគមន៍ជាច្រើនបានរីកឡើងដូចផ្សិតក្នុងរយៈពេលមួយទសវត្សចុងក្រោយនេះក្នុងផ្នែកថ្មីៗជាច្រើនដែលប៉ះពាល់សហគមន៍របស់ពួកគេរាប់ពីបរិស្ថាន ការផ្តល់សេវា សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ។ អង្គការសហគមន៍ទាំងនេះ ជាមួយនឹងវត្តមានរបស់ពួកគេ អាចនឹងមានបេសកកម្មជាក់លាក់ និងអភិបាលកិច្ចរឹងមាំ។ សហប្រតិបត្តិការជាមួយអង្គការសហគមន៍ដែលមានស្រាប់ជាច្រើនគឺសំខាន់ណាស់ព្រោះពួកគេតំណាងឱ្យភាគច្រើននៃប្រជាពលរដ្ឋសហគមន៍។ ប្រការនេះក៏ធានាផងដែរនូវនិរន្តរភាពនៃអន្តរកម្មល្អ និងការតស៊ូមតិដែលដាក់ចេញដោយ API។

### ការធ្វើការជាមួយទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ

វាសមហេតុផល សម្រាប់ API ដើម្បីរក្សាការផ្តោតលើវិធីដែលយកសិទ្ធិជាគោល (right-based approach) ក្នុងការអភិវឌ្ឍដែលអភិវឌ្ឍសមត្ថភាពកាតព្វកិច្ចករ (អ្នកមានកាតព្វកិច្ច duty-bearers) ឱ្យបំពេញតាមកាតព្វកិច្ចនានារបស់ពួកគេ និងលើកទឹកចិត្តឱ្យសិទ្ធិករ (អ្នកមានសិទ្ធិ rights holders) ឱ្យទារសិទ្ធិទាំងឡាយរបស់ពួកគេ។ វាពិតណាស់ កិច្ចការយុទ្ធសាស្ត្រមួយសម្រាប់ NGOs គឺការពង្រឹងអង្គការសហគមន៍ និងប្រជាពលរដ្ឋជាច្រើននៅកម្រិតមូលដ្ឋាន ឱ្យពួកគេបានរឹងមាំក្នុងការតស៊ូមតិឱ្យបរិយាកាសអំណោយផលច្រើនមួយ ក៏ដូចជា ការឆ្លើយតបនឹងបញ្ហាមូលដ្ឋានជាក់លាក់មួយដែលប៉ះពាល់ជីវិតរបស់ពួកគេ។ ប្រការនេះត្រូវការកាតព្វកិច្ចករជាច្រើនអនុវត្តស្របតាមតម្រូវការកាតព្វកិច្ចទាំងឡាយរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារសមត្ថភាពនៃកាតព្វកិច្ចករជាច្រើនគឺនៅមានកម្រិតនោះ ដោយសារការអភិវឌ្ឍសមត្ថភាពមិនគ្រប់គ្រាន់ និងការផ្លាស់ប្តូរញឹកញាប់នៃសមាជិកភាពនៅក្នុងការបោះឆ្នោតរាល់លើកនោះ ការពង្រឹងសមត្ថភាពក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិសំខាន់ណាស់។ នៅពេលសិទ្ធិករ (អ្នកម្ចាស់សិទ្ធិ) យល់អំពីសិទ្ធិរបស់ពួកគេក្នុងការទារ និងអាចអនុវត្តសិទ្ធិក្នុងវិធីសមរម្យមួយ ហើយកាតព្វកិច្ចករ (អ្នកមានកាតព្វកិច្ច) ទាំងឡាយបំពេញមុខងាររបស់ពួកគេត្រូវតាមកាតព្វកិច្ចទាំងឡាយរបស់ពួកគេនោះ អន្តរកម្មរវាងពួកគេមុខជាកាន់តែមានន័យច្រើនឡើង។ ការកសាងទំនុកចិត្ត និងសម្ព័ន្ធភាពការងារល្អរវាងផ្នែកផ្គត់ផ្គង់ និងផ្នែកទាមទារមុខជានាំមកផងដែរនូវការផ្លាស់ប្តូរវិជ្ជមានជាច្រើននៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូច្នេះ ការឱ្យពួកគេចូលពាក់ព័ន្ធក្នុងព្រឹត្តិការណ៍រួមគ្នាទាំងអស់ ដូចជា ការឆ្លុះបញ្ចាំងប្រចាំឆ្នាំ ការប្រជុំដៃគូទៀងទាត់ និងទស្សនកិច្ចសិក្សាមុខជារួមចំណែកជាដុំកំភួនដល់រឿងនេះ។

# របាយការណ៍បីឆ្នាំ ២០១៩-២១

## ការប្រើយន្តការអនឡាញ/ប្រព័ន្ធផ្សព្វផ្សាយបណ្ដាញសង្គម និងអន្តរកម្មក្រៅឡាញ (offline interaction)

មកពីការអនុវត្តកម្មវិធី/គម្រោងរបស់ API ក្នុងអំឡុងពេលនៃការសាយភាពនៃការផ្ទុះជំងឺកូវីដ-១៩ វាគឺច្បាស់ណាស់ថា បច្ចេកទេសព័ត៌មាន និងការប្រាស្រ័យទាក់ទងជាច្រើន (ICT) ដើរតួនាទីសំខាន់ខ្លាំងមួយក្នុងរជ្ជកាលឌីជីថលនេះ។ វាជួយបុគ្គលិក និងថ្នាក់ដឹកនាំរបស់ API ក្នុងការប្រាស្រ័យទាក់ទងប្រចាំថ្ងៃ សហប្រតិបត្តិការ និងធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការអនុវត្តគម្រោង ដោយសារការកំហិតដែលដាក់ដោយរដ្ឋាភិបាលសម្រាប់បង្ការការសាយភាយការផ្ទុះជំងឺកូវីដ-១៩។ នៅកម្រិតមូលដ្ឋាន ការប្រើ ICT នាំឱ្យមានការទៅដល់ប្រជាជនដែលពាក់ព័ន្ធច្រើនឡើង ក្នុងវិធីមួយដែលលឿន សុក្រិត និងប្រសិទ្ធភាពចំណាយ។ ទោះជាយ៉ាងណាក៏ដោយ វាត្រូវការឱ្យអ្នកប្រើមានចំណេះដឹងមូលដ្ឋានខ្លះខាងយន្តការ និងឧបករណ៍ ICT នានា ហើយផងដែរ វាត្រូវការឱ្យមានសេវាអ៊ីនធឺណេត និងអគ្គីសនីដែលមិនរអាក់រអួល។ យ៉ាងណាមិញ យន្តការអនឡាញមិនសូវមានប្រយោជន៍ខ្លាំងទេ ហើយវាហាក់ដូចជាមិនសូវមានផលិតភាពជាងការធ្វើការផ្ទាល់ ដោយសារវាមិនមែនជាអន្តរកម្មទល់គ្នាផ្ទាល់ ហើយវាត្រូវធ្វើតាមរយៈយន្តការមួយដែលពេលខ្លះ គេមិននិយមសម្រាប់ការប្រាស្រ័យទាក់ទង។ ដូច្នេះ បន្សំនៃអន្តរកម្មអនឡាញ និងក្រៅឡាញ (offline) អាចមានផលិតភាព។

## ការចូលរួមនៃបុរស និងស្ត្រី

ការសង្កេតពីដើមដល់ចប់ក្នុងការពិភាក្សាចំណាប់អារម្មណ៍ (FGD) ស្ត្រីអាចបញ្ចេញគំនិត/មតិរបស់ពួកគេដោយសេរីបាន តែនៅក្នុងក្រុមស្ត្រីប៉ុណ្ណោះ។ នៅពេលដែលពួកគេ ត្រូវបានដាក់លាយគ្នាជាមួយបុរសនោះ បុរសនឹងគ្របសង្កត់លើការពិភាក្សានានា។ ប្រការនេះឆ្លុះបញ្ចាំងឱ្យឃើញការពិតដែលស្ត្រីជាច្រើនគឺសកម្មខ្លាំងនៅកម្រិតសកម្ម ប៉ុន្តែមិនសូវសកម្មនៅកម្រិតធ្វើការសម្រេចចិត្ត។ ដូច្នេះ ការឆ្លាតសម្រាប់ NGOs ក្នុងធ្វើការជាមួយបុរស និងស្ត្រី គឺត្រូវផ្តោតច្រើនលើស្ត្រី ដើម្បីសម្រេចបានការប្រែប្រួលខាងយេនឌ័រ មិនថាដំណាលគ្នាឬបន្តបន្ទាប់គ្នា ដោយមានក្រុមភេទតែមួយជាច្រើនក្រុម និងក្រុមចម្រុះភេទច្រើនក្រុម។ វាគឺសំខាន់ក្នុងការផ្តល់ដល់ទាំងបុរស និងស្ត្រីនូវលម្ហសុវត្ថិភាពជាច្រើនដែលពួកគេអាចពិភាក្សា និងឆ្លុះបញ្ចាំងលើវិធីនានាដែលនៅក្នុងនោះ បទដ្ឋានយេនឌ័រជាច្រើនមានឥទ្ធិពលលើជីវិតរបស់ពួកគេ និងជីវិតរបស់អ្នកដទៃទៀត។

## ការធ្វើការជាមួយយុវជន

ដើម្បីបំពេញការខ្វះខាតជាច្រើននៃអវត្តមានការិយាល័យមូលដ្ឋានរបស់ API API លៃលកធ្វើការជាមួយអ្នកហាត់ការ និងអ្នកស្ម័គ្រចិត្ត/បុគ្គលិកពាក់កណ្ដាលពេលជាច្រើននាក់ដែលជាយុវជននៅកម្រិតមូលដ្ឋាន និងមានសាវតាខុសៗគ្នា ភាពងាយរងគ្រោះ និង ពូជសាសន៍ផ្សេងគ្នា។ ប្រការនេះហាក់ដូចជាមានប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការជួយសម្រេចបានលទ្ធផលរបស់API ធៀបនឹងលទ្ធផល/ឥទ្ធិពលរំពឹងទុករបស់វាដែលបានកំណត់ដោយយុទ្ធសាស្ត្រ និងគម្រោងនានារបស់ API។ ពួកគេត្រូវបានជ្រើសរើសជាបន្តបន្ទាប់ជាបុគ្គលិកពេញម៉ោង នៅពេលដែលសមត្ថភាពពួកគេសមនឹងការងារនានាដែលគេត្រូវការ។ ប្រការនេះគឺពិតជាល្អណាស់ មិនត្រឹមតែសម្រាប់ការដាក់បញ្ចូលមនុស្សថ្មីទៅក្នុង API ប៉ុណ្ណោះទេ ប៉ុន្តែវាបង្ហាញផងដែរនូវអត្ថប្រយោជន៍ដែលទូទាត់គ្នាបានរបស់ API ក្នុងការធ្វើការជាមួយតួអង្គដែលច្បាស់លាស់បំផុតសម្រាប់អនាគតរបស់ប្រទេសកម្ពុជា។ ការកសាងសមត្ថភាពយុវជន[1] រួមចំណែកដល់ការកសាងប្រជាពលរដ្ឋសកម្មជាច្រើននាក់ដែលអាចច្បាស់លាស់ជាយថាហេតុសម្រាប់អត្រាចំណេញនាពេលអនាគត។

# របាយការណ៍បីឆ្នាំ ២០១៩-២១

ការតស៊ូមតិបែបទន់

API អនុវត្តវិធីទន់ក្នុងការតស៊ូមតិរបស់វាសម្រាប់ការដាក់ឥទ្ធិពលលើគោលនយោបាយ និងផងដែរក្នុងដំណើរការដោះស្រាយបញ្ហាមូលដ្ឋាន។ ការតស៊ូមតិបែបទន់មិននាំមកនូវការខូចខាត/គ្រោះថ្នាក់ដល់ដៃគូរបស់ API រួមទាំង NGOs និងអង្គការសហគមន៍ ហើយវាត្រូវបានពេញចិត្តយ៉ាងខ្លាំងដោយរដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ ការប្រើវិធីតស៊ូមតិបែបទន់មិនទំនងជាខ្លាំងសម្រាប់ការដាក់ឥទ្ធិពលលើគោលនយោបាយទេ ដូចបានបង្ហាញក្នុងដំណើរការបង្កើតពង្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន (A2I) ដែលចំណាយពេលស្ទើរតែ១០ឆ្នាំសម្រាប់ការបង្កើត និងការបញ្ចប់។ ដូច្នេះ ការធ្វើការដោយសហការជាមួយដៃគូដទៃទៀតជាច្រើន[2] ដែលមានសមត្ថភាពអនុវត្តទ្រង់ទ្រាយផ្សេងទៀតជាច្រើននៃការតស៊ូមតិ និងជាមួយអង្គការសហគមន៍ និងប្រជាពលរដ្ឋដើម្បីទាមទារការផ្លាស់ប្តូរគោលនយោបាយអាចមានប្រសិទ្ធភាពច្រើន។

## ៣ អនុសាសន៍សម្រាប់អនាគត់

ការកសាងពីលើការវិភាគការសម្រេចបាននានា ផ្នែកដែលត្រូវយកចិត្តទុកដាក់ និងមេរៀនសំខាន់ៗ ខាងក្រោមនេះគឺជាអនុសាសន៍ផ្សេងៗសម្រាប់ API ផ្តោតការយកចិត្តទុកដាក់ នៅពេលតាក់តែងផែនការយុទ្ធសាស្ត្រក្នុងពេលអនាគត។

ការដាក់ឥទ្ធិពលលើគោលនយោបាយ

វាមានតម្លៃក្នុងការកត់សម្គាល់ការរួមចំណែកធំធេងរបស់ API ដល់ការបញ្ចប់ជាស្ថាពរនូវពង្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន (A2I) ដែលឥឡូវនេះគឺរួចរាល់ដើម្បីបញ្ជូនបន្តទៅទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គនីតិបញ្ញត្តិសម្រាប់ការពិនិត្យមើលចុងក្រោយ និងការអនុម័ត។ នៅពេលវាក្លាយជាច្បាប់មួយហើយនោះ មានបទបញ្ញត្តិសំខាន់ៗមួយដែលត្រូវការឱ្យគេបង្កើតឡើង ពិភាក្សា និងដាក់អនុវត្ត។ API គួរធ្វើការជាមួយទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ និងទីភ្នាក់ងារសហប្រជាជាតិដែល អង្គការ NGOs និងអង្គការសហគមន៍ដែលពាក់ព័ន្ធនានាដើម្បីផ្តល់ធាតុចូល ដើម្បីធានាថាច្បាប់មុខជាត្រូវបានអនុវត្តដើម្បីផលចំណេញផ្សេងៗនៃសង្គមទាំងមូល ជាពិសេសនៅកម្រិតសហគមន៍។ ការអនុវត្តច្បាប់ដើម្បីឱ្យដំណើរការបើកចំហថវិកាអាចធ្វើទៅបាននៅកម្រិតជាតិ និងថ្នាក់ក្រោមជាតិនោះ គឺវាគួរជាអាទិភាពខ្ពស់មួយរបស់ API។

ក្នុងឋានៈជាម្ចាស់ផ្ទះ/លេខាធិការដ្ឋាននៃអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) វាគឺសំខាន់ចំពោះ API ដើម្បីធានាឯករាជ្យភាព និងសមត្ថភាពនៃអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) ក្នុងតំណាងអង្គការហគមន៍នៅក្នុងវិស័យវិមជ្ឈការ និងវិសហមជ្ឈការ (D&D)។ កៅអីនៃ CPDD នៅលេខាធិការដ្ឋាននៃគណកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDDS) គួរត្រូវបានពិភាក្សា និងបញ្ជាក់ឱ្យច្បាស់ជាមួយភាគីពាក់ព័ន្ធទាំងឡាយ និងNCDDS។ ផងដែរ គេគួរពង្រឹងតួនាទីរបស់គណៈកម្មាធិការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ CPDD គឺត្រូវពាក់ព័ន្ធយ៉ាងសកម្មជាមួយដំណើរការត្រួតពិនិត្យការអនុវត្តកម្មវិធីជាតិទីពីរនៃគណៈកម្មាធិការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ២០២១-២០៣០ (NP-NSDD 2021-2030)។ ទីមួយ API នឹងត្រូវការគាំទ្រអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) ក្នុងការលើកស្ទួយការយល់រួមគ្នាក្នុងចំណោមសមាជិកទាំងឡាយនៃ CPDD និងអង្គការសហគមន៍មូលដ្ឋានអំពីការសម្រេចបាន និងកត្តាប្រឈមនៃកម្មវិធីជាតិនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDDD) ដំណាក់កាលទី១ និងចំណុចខ្លាំង និងកំហិតនៃកម្មវិធីជាតិនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

# របាយការណ៍បីឆ្នាំ ២០១៩-២១

នៅថ្នាក់ក្រោមជាតិ (NP-SNDD) ដំណាក់កាលទី២។ ទីពីរ កសាងពីលើការយល់ឃើញរួមអំពីកម្មវិធីជាតិនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) API នឹងត្រូវការគាំទ្រអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) ក្នុងការចម្រាញ់យកយោបល់ និងធាតុចូលផ្សេងៗសម្រាប់ធ្វើឱ្យប្រសើរឡើងនូវផែនការជាតិនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ដំណាក់កាលទី២។ ទីបី API នឹងត្រូវការគាំទ្រ CPDD ដើម្បីធ្វើឱ្យបានដល់អតិបរមានូវបណ្តាញរបស់វាជាមួយទីភ្នាក់ងារនៃសហប្រជាជាតិ NGOs និងអង្គការសហគមន៍ និងទំនាក់ទំនងរបស់វាជាមួយក្រសួង/ស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាល ដើម្បីដាក់ឥទ្ធិពលលើលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដើម្បីបញ្ចប់ជាស្ថាពរនូវកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ដំណាក់កាលទី២ក្នុងការឆ្លើយតបនឹងយោបល់/ធាតុចូលផ្សេងៗដែលផ្តល់ដោយអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)។

## ការពាក់ព័ន្ធរបស់ប្រជាពលរដ្ឋ

មានកិច្ចការសំខាន់ៗចំនួនពីរដែលត្រូវធ្វើដើម្បីបើកចំហឱ្យមានការចូលពាក់ព័ន្ធរបស់ប្រជាពលរដ្ឋ ដែលផ្អែកជាចម្បងលើប្រជាពលរដ្ឋជាច្រើនដែលសកម្ម (អ្នកម្ចាស់សិទ្ធិ) និងសមត្ថភាពជាច្រើនដើម្បីបំពេញតួនាទី កាតព្វកិច្ច និងការទទួលខុសត្រូវផ្សេងៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) (អ្នកមានកាតព្វកិច្ចនានា)។ ការធ្វើការជាមួយតួអង្គទាំងពីរនេះមុខជានឹងជំរុញការពាក់ព័ន្ធពីប្រជាពលរដ្ឋជាច្រើនក្នុងអភិបាលកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ពួកគេត្រូវធ្វើការប្រកបដោយការសហការជាមួយគ្នាទៅវិញទៅមកក្នុងបរិបទនៃវិធីដែលផ្អែកលើសិទ្ធិ (rights-based approach) ដែលនាំឆ្ពោះទៅរកការអភិវឌ្ឍសមត្ថភាពរបស់អ្នកមានកាតព្វកិច្ច (duty-bearers) ដើម្បីធ្វើការត្រូវតាមកាតព្វកិច្ចនានារបស់ពួកគេ និងលើកទឹកចិត្តអ្នកម្ចាស់សិទ្ធិ (rights holders) ដើម្បីទាមទារសិទ្ធិរបស់ពួកគេ។

API គួរសម្របសម្រួលឱ្យមានជម្រើសល្អបំផុតនានាសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការដាក់ចេញនូវវិធីធ្វើការជាច្រើនសម្រាប់ការចូលរួមដែលប្រសើរឡើង។ វិធីធ្វើការនានាមានរួមទាំងដំណើរការធ្វើផែនការ និងការធ្វើថវិកាមូលដ្ឋាន ទាំងផែនការវិនិយោគឃុំ (CIP) និងផែនការអភិវឌ្ឍន៍ឃុំ (CDP) ប្រជុំប្រចាំខែ កិច្ចប្រជុំផ្សព្វផ្សាយការយល់ដឹងនៅសហគមន៍ និងវេទិកាសាធារណៈ។ API មានយុទ្ធសាស្ត្រល្អមួយក្នុងការធ្វើការជាមួយក្រុមមានសំឡេងតិច/ក្រុមត្រូវគេមិនអើពើរ (voiceless/marginalized) ដូចជាស្ត្រី ជនជាតិដើមភាគតិច (Ips) និងជនមានពិការភាព (PWDs) ដើម្បីធ្វើឱ្យប្រសើរឡើងនូវសំឡេងរបស់ពួកគេសម្រាប់ការអភិវឌ្ឍចីរភាព។ គេគួរកំណត់ក្រុមមានសំឡេងតិច/ក្រុមត្រូវគេរើសអើងជាច្រើនដើម្បីធ្វើការជាមួយអ្នករស់រានពីហិង្សាជាច្រើន មានដូចជា អ្នកស្រឡាញ់ភេទដូចគ្នា (lesbian) ខ្ទើយ (gay) អ្នកមានភេទពីរ (bisexual) និងអ្នកកែភេទ (transgender) (ជន LGBT) និងមនុស្សចាស់ព្រឹទ្ធាចារ្យ។ API គួរពាក់ព័ន្ធពួកគេជាអ្នកស្ម័គ្រចិត្តមូលដ្ឋាននានាដែលបំពាក់ចំណេះដឹង និងជំនាញដើម្បីពួកគេអាចធ្វើការដោយប្រសិទ្ធភាពដើម្បីដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេជាច្រើន ក៏ដូចជាការបារម្ភនៃក្រុម និងសហគមន៍របស់ពួកគេនានា។ ត្រង់ចំណុចនឹងពេលណាដែលអាចទៅរួច API គួរជ្រើសរើសពួកគេទៅជាបុគ្គលិករបស់ API ផងដែរ ដើម្បីបង្ហាញឱ្យឃើញអត្ថប្រយោជន៍ជាច្រើនដែលប្រៀបធៀបបានខ្លាំងក្លានៃ APIក្នុងឋានៈជាអង្គការមួយដែលធ្វើការជាមួយក្រុមមានសំឡេងតិច/ក្រុមត្រូវបានគេមិនអើពើរ(voiceless/marginalized) សម្រាប់ការអភិវឌ្ឍដោយចីរភាព។

# របាយការណ៍បីឆ្នាំ ២០១៩-២១

អង្គការសហគមន៍គឺតំណាងបានល្អបំផុតនូវផលប្រយោជន៍មូលដ្ឋាន។ API គួរប្រើឱ្យមានប្រយោជន៍នូវអង្គការសហគមន៍ដែលមានស្រាប់នានាដែលចងក្រងដោយខ្លួនឯងដែលមានរបៀបវារៈជាក់លាក់សម្រាប់ការតស៊ូមតិ និងការងារនៅក្នុងរចនាសម្ព័ន្ធអង្គការច្បាស់លាស់របស់ពួកគេ ដូចជាក្រុមគ្រប់គ្រងធនធានធម្មជាតិ (NRM) ជនជាតិដើមភាគតិច (IP) ជនមានប័ណ្ណក្រីក្រ (PWD) ក្រុមអ្នកលក់ដូរតាមចិញ្ចើមផ្លូវ និងក្រុមយុវជនផ្សេងៗដើម្បីដាក់ឥទ្ធិពលលើដំណើរការសម្រេចចិត្តនៅកម្រិតស្រុក/ក្រុង/ខណ្ឌ។ ចំពោះការពាក់ព័ន្ធប្រកបដោយអត្ថន័យ API គួរកសាងសមត្ថភាពរបស់អង្គការសហគមន៍ ក្នុងការកំណត់ក្តីបារម្ភ/បញ្ហានានាពីសហគមន៍របស់ពួកគេសម្រាប់ឱ្យមានការយកចិត្តទុកដាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ គំរូល្អនៃការកំណាត់បញ្ហាដែលបានប្រើក្នុងគណនេយ្យភាពសង្គម (ISAF)គួរត្រូវបានអនុវត្តនៅក្នុងឃុំ/សង្កាត់ដែលមិនអនុវត្តគណនេយ្យភាពសង្គមដើម្បីដោះស្រាយបញ្ហាដោយប្រសិទ្ធភាព។ ជំនាញទន់មួយចំនួនគួរពិចារណាសម្រាប់ការបណ្តុះបណ្តាលឬការបណ្តុះបណ្តាលរំឭក ដល់អង្គការសហគមន៍ ដូចជាការដោះស្រាយបញ្ហា ការប្រាស្រ័យទាក់ទង ការសម្របសម្រួល ការចរចារ និងការធ្វើបទបង្ហាញ។ ពួកគេគួរបំពាក់ជំនាញ ICT ដូចជា ការប្រើយន្តការអនឡាញផ្សេងៗ និងបណ្តាញផ្សព្វផ្សាយសង្គមសម្រាប់ការប្រាស្រ័យទាក់ទងប្រចាំថ្ងៃ។ ជំនាញអង្គការ ដូចជារដ្ឋបាល និងហិរញ្ញវត្ថុ និងការគ្រប់គ្រងគម្រោង និងការអភិវឌ្ឍសំណើគួរត្រូវបានពិចារណាផ្តល់ដល់អង្គការសហគមន៍។

បន្ថែមលើការកសាងសមត្ថភាព API គួរពិចារណាពាក់ព័ន្ធអង្គការសហគមន៍ជាមួយបណ្តាញ ច្រើនប្រភេទដើម្បីពង្រឹងអំណាចតថ្លៃសម្រាប់អង្គការសហគមន៍ទាមទាររដ្ឋបាលថ្នាក់ក្រោមជាតិឱ្យឆ្លើយតបនឹងបញ្ហាសំខាន់ៗដែលលើកឡើងដោយប្រជាពលរដ្ឋជាច្រើន។ មានយន្តការកម្រិតខេត្ត និងជាតិជាច្រើន ដូចជា ក្រុមការងារគណនេយ្យភាពសង្គម (SAWG) សម្ព័ន្ធភាពក្រុមប្រឹក្សាមូលដ្ឋាន (NLC) សមាគមជាតិនៃក្រុមប្រឹក្សាខេត្ត និងក្រុង (NACPC) និងសមាគមនៃក្រុមប្រឹក្សារដ្ឋាបាលថ្នាក់ក្រោមជាតិ (ASAC) ដែលអាចដាក់ឥទ្ធិពលលើគណនេយ្យភាពនៃអាជ្ញាធរឃុំ/សង្កាត់ និងស្រុក/ខណ្ឌ។

ការកសាងសមត្ថភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស ឃុំ/សង្កាត់ និងស្រុក/ខណ្ឌ (អ្នកមានកាតព្វកិច្ចនានា) អាចនឹងធ្វើឱ្យពួកគេបំពេញគណនេយ្យភាពរបស់ពួកគេ ជាពិសេសប្រជាពលរដ្ឋជាច្រើនដែលជាម្ចាស់ឆ្នោត។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវដឹងឱ្យច្បាស់អំពីតួនាទី កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ពួកគេដែលចាំបាច់ត្រូវបំពេញឱ្យបានល្អបំផុត ក្នុងការឆ្លើយតបនឹងក្តីបារម្ភ/តម្រូវការផ្សេងៗរបស់ប្រជាពលរដ្ឋ (អ្នកម្ចាស់សិទ្ធិ) និងសិទ្ធិ និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋផងដែរ ដើម្បីឱ្យពួកគេអាចទំនាក់ទំនងទៅវិញទៅមកប្រកបដោយអត្ថន័យ។ API គួរធ្វើការជាមួយដៃគូដទៃទៀតដែលអាចកសាងសមត្ថភាពរបស់អ្នកមានកាតព្វកិច្ចយ៉ាងមានប្រសិទ្ធភាព ឬវាអាចរុករកឱកាសផ្តល់មូលនិធិជាមួយម្ចាស់ជំនួយសក្តានុពលនៅក្នុងកម្មវិធី/គម្រោង ដែលកំពុងដំណើរការរបស់ខ្លួន។[3]





# របាយការណ៍បីឆ្នាំ ២០១៩-២១

API គួរណែនាំផងដែរដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងក្រុមប្រឹក្សាស្រុក/ក្រុង/ខណ្ឌក្នុងការរៀបចំប្រជុំ/វេទិការបស់ពួកគេដោយប្រសិទ្ធភាព។ ពួកគេគួរធ្វើការជិតដិតជាមួយអង្គការសហគមន៍ក្នុងការកំណត់រឿង/បញ្ហាមូលដ្ឋានជាច្រើនមុននឹងប្រជុំ/វេទិកា និងដើម្បីធ្វើឱ្យច្បាស់ថាគ្រប់បញ្ហាត្រូវបានកំណត់ និងនាំយកមកក្នុងកិច្ចប្រជុំ/វេទិកា។ ដូចគ្នានឹងអង្គការសហគមន៍ដែរ ក្រុមប្រឹក្សាឃុំ/សង្កាត់ និងក្រុមប្រឹក្សាស្រុក/ក្រុង/ខណ្ឌគួរបំពាក់ផងដែរនូវជំនាញទន់មួយចំនួនសម្រាប់ការបំពេញតួនាទី កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ពួកគេសម្រាប់ការបំពេញតួនាទី កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ពួកគេបានល្អប្រសើរឡើង ដូចជាការដោះស្រាយបញ្ហា ការប្រាស្រ័យទាក់ទង ការសម្របសម្រួល ការចរចារ និងការធ្វើបទបង្ហាញ និងជំនាញ ICT ផងដែរ ដូចជាការប្រើយន្តការអនឡាញនានា និងបណ្តាញផ្សព្វផ្សាយសង្គមផ្សេងៗសម្រាប់ការប្រាស្រ័យទាក់ទងប្រចាំថ្ងៃ។ កិច្ចប្រជុំប្រចាំខែចល័តរបស់ពួកគេជាមួយសហគមន៍គួរត្រូវបានលើកទឹកចិត្ត។ API គួរជួយកសាងផងដែរនូវសមត្ថភាពរបស់ពួកគេក្នុងការប្រើ ICT online platforms និងបណ្តាញផ្សព្វផ្សាយសង្គមដើម្បីប្រាស្រ័យឱ្យបានពេញលេញជាមួយសាម៉ីជនទាំងអស់ ជាពិសេស អង្គការសហគមន៍ និងប្រជាពលរដ្ឋនានា។

**<u>ធ្វើឱ្យប្រសើរឡើងនូវសិទ្ធិទទួលបានព័ត៌មាន</u>**

ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រុមប្រឹក្សាឃុំ/សង្កាត់ និងស្រុក/ក្រុង/ខណ្ឌ) វិធីសាស្រ្តដែលគេបានប្រើសម្រាប់បង្កើនការពាក់ព័ន្ធប្រកបដោយអត្ថន័យជាមួយប្រជាពលរដ្ឋគួរត្រូវបានធ្វើឱ្យប្រសើរឡើង។

- កិច្ចប្រជុំប្រចាំខែតាមមូលដ្ឋាននានា ដូចបានផ្តួចផ្តើម/បានអនុវត្តដោយក្រុងពោធិ៍សាត់នៃខេត្តពោធិ៍សាត់ និងឃុំត្បូងក្រពើនៃខេត្តកំពង់ធំគួរត្រូវបានចម្លងទៅទីតាំងជាច្រើនដទៃទៀត។
- យន្តការអនឡាញជាច្រើនរួមទាំងបណ្តាញផ្សព្វផ្សាយសង្គម (ដូចជា ទំព័រហ្វេសប៊ុកផ្លូវការនៃឃុំ/សង្កាត់ និងស្រុក/ក្រុង/ខណ្ឌ) គួរត្រូវបានបង្កើតឡើង ដំណើរការ និងសកម្មសម្រាប់លើកស្ទួយការប្រាស្រ័យទាក់ទង និងការចូលរួមពីប្រជាពលរដ្ឋជាច្រើន។ API គួរអាចជួយពួកគេក្នុងការបង្កើត និងដំណើរការទំព័រហ្វេសប៊ុកទាំងនេះ។
- យ៉ាងហោចណាស់ API ឬអង្គការសហគមន៍គួរស្នើបង្កើតក្តារផ្សព្វផ្សាយមួយនៅតាមផ្ទះប្រធានភូមិនីមួយៗ ឬនៅទីតាំងសមរម្យណាមួយដែលប្រជាជនអាចចូលទៅប្រើប្រាស់វាបានស្រួល។ ព័ត៌មានដែលត្រូវបង្ហាញលើក្តារផ្សព្វផ្សាយគួរបញ្ចូលផែនការអភិវឌ្ឍន៍ឃុំដែលជាអាទិភាពរយៈពេលវែង ហើយគួរច្បាស់លាស់ និងចំៗដើម្បីងាយស្រួលយល់ និងទាក់ទាញពីអ្នកអាននានា។ បន្ថែមពីលើនេះ វិធីជាច្រើនដទៃទៀតសម្រាប់ការផ្សព្វផ្សាយព័ត៌មាន ឧទាហរណ៍ តាមរយៈមេក្រូចល័តជាច្រើនគួរអនុវត្តផងដែរ។





# របាយការណ៍បីឆ្នាំ ២០១៩-២១

- មន្ត្រីជាច្រើនមកពីរដ្ឋបាលថ្នាក់ក្រោមជាតិគួរត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងកិច្ចប្រជុំ/ប្រមូលផ្តុំដែលផ្តួចផ្តើមដោយខ្លួនឯង ដើម្បីយល់ពីភាពពិតអំពីបញ្ហានានាដែលបានកើតឡើង និងដើម្បីអន្តរាគមន៍នៅពេល និងត្រង់ណាដែលអាចទៅរួច។

ក្នុងរយៈវែង ការធ្វើឱ្យយន្តការឌីជីថលដែលមានស្រាប់នានា នឹងគ្រឹះចំពោះ API ដើម្បីធានាយន្តការដែលមានប្រសិទ្ធភាពសម្រាប់ប្រជាពលរដ្ឋមានសិទ្ធិជាក់ស្តែងក្នុងការផ្តល់ និងទទួលបានព័ត៌មានទុកចិត្តបានពីរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជា ដើម្បីចូលរួមប្រកបដោយអត្ថន័យជាមួយសេវារដ្ឋបាលថ្នាក់ក្រោមជាតិ។ API NGOs ដៃគូ និងអ្នកផ្តល់មូលនិធិត្រូវពិភាក្សារួមគ្នា និងបង្កើតផែនការចីរភាពសម្រាប់យន្តការឌីជីថលដែលមានស្រាប់ទាំងអស់។

API ត្រូវតែធ្វើច្រើនថែមទៀតទាក់ទងនឹងការកសាងការដឹងឮ និងការយល់អំពីសេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីបើកចំហព័ត៌មានសំខាន់ៗដល់សាធារណជន។ ក្រៅពីធ្វើការជាមួយអង្គការសហគមន៍ និងប្រជាពលរដ្ឋមូលដ្ឋានជាច្រើន និស្សិតសកលវិទ្យាល័យ អ្នកស្រាវជ្រាវ អ្នករៀនសូត្រជាន់ខ្ពស់ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិក្រឹតការគួរត្រូវបានគេរុករកសក្តានុពល។ API គួរធ្វើការជាមួយសកលវិទ្យាល័យ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលនានា (ដូចជា សាលាភូមិន្ទរដ្ឋបាល វិទ្យាស្ថានអប់រំជាតិ និងសាលាភូមិន្ទរដ្ឋបាលមូលដ្ឋាន) ដើម្បីបញ្ចូលប្រធានបទគន្លឹះៗមួយចំនួនដែលទាក់ទងនឹងការផ្តល់សេវាសាធារណៈ ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិ វិធីដែលយកសិទ្ធិជាមូលដ្ឋាន (rights-based approach) ការធ្វើថវិកាដែលនិយមអ្នកក្រ (pro-poor budgeting) គណនេយ្យភាពសង្គម និងប្រធានបទដទៃទៀតមួយចំនួនដែលទាក់ទងនឹងការធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពរដ្ឋាភិបាល។ ការបង្រៀនជាច្រើនស៊េរីតាមប្រធានបទគន្លឹះផ្សេងដែលបានលើកឡើងខាងលើគួរត្រូវបានរៀបចំដោយដៅលើយុវជនដែលមកពីសកលវិទ្យាល័យ អ្នកស្រាវជ្រាវ និងបណ្ឌិតសភា។

## ពង្រឹងកិត្តិសព្ទនៃអង្គការ

វាគឺសំខាន់ចំពោះ API ក្នុងការបង្ហាញដល់សាធារណជនថា អង្គការមានមុខងារអភិបាលកិច្ច និងគ្រប់គ្រងរឹងមាំ និងធនធានជាច្រើនដើម្បីគាំទ្រកម្មវិធីនានារបស់ខ្លួន។

## ការដឹកនាំ និងអភិបាលកិច្ច

ការដឹកនាំមិនគួរពឹងផ្អែកលើតែនាយកប្រតិបត្តិប៉ុណ្ណោះទេ។ ការដឹកនាំរឹងមាំគឺយ៉ាងហោចណាស់ មានមួយចំណែកមកពីមនុស្សមួយក្រុមដែលមិនពាក់ព័ន្ធនឹងប្រតិបត្តិការរបស់អង្គការ។ ការទទួលខុសត្រូវនៃក្រុមប្រឹក្សាភិបាលគួរជាការដឹកនាំរឹងមាំ។ ប្រសិនបើមានការឈានឡើងក្នុងការធ្វើតួនាទីក្នុងស្តង់ដារនៃក្រុមប្រឹក្សាភិបាលរបស់ API វាគួរមានការជជែកថា (ប្រសិនបើពួកគេបានអនុវត្តតួនាទីរឹងមាំមួយ) ពួកគេទទួល "ថ្លៃឈ្នួលការងារ sitting fees" ដើម្បីទូទាត់សងដល់ពួកគេសម្រាប់ការធ្វើជាក្រុមប្រឹក្សាភិបាលមួយដែលសកម្ម និងមានសមត្ថភាព។ វាត្រូវបានទទួលស្គាល់ថាការធ្វើជាក្រុមប្រឹក្សាភិបាលគឺលំបាក និងមានតួនាទីសំខាន់។

តួនាទី និងមុខងារជាច្រើនរបស់ក្រុមប្រឹក្សាភិបាលរបស់ API គួរត្រូវបានដំឡើងទៅជាការដឹកនាំអង្គការ API ពេញលេញ ដូចជាក្រុមប្រឹក្សាភិបាលគួរគ្រប់គ្រងសវនកម្ម និងការវាយតម្លៃអង្គការ/យុទ្ធសាស្ត្រទាំងមូល បន្ថែមលើកិច្ចការធម្មតារបស់ខ្លួនដែលកំណត់ក្នុងលក្ខន្តិកៈបច្ចុប្បន្ន។ យន្តការនានាសម្រាប់ក្រុមប្រឹក្សាភិបាលធ្វើការប្រាស្រ័យទាក់ទង និងការទទួលបានយោបល់ត្រឡប់ផ្ទាល់ពីបុគ្គលិក អ្នកទទួលផល និងអ្នកពាក់ព័ន្ធសំខាន់ៗរបស់ API គួរត្រូវបង្កើត និងប្រតិបត្តិដោយក្រុមប្រឹក្សាភិបាល។ ការតាមដានការសម្រេចចិត្ត និងសកម្មភាពរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឱ្យឱ្យបានចិតថេរ។

# របាយការណ៍បីឆ្នាំ ២០១៩-២១

ក្រុមប្រឹក្សាភិបាលត្រូវការមានមូលនិធិដើម្បីអនុវត្តមុខងាររបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព ដូចជា ការជួលទីប្រឹក្សាដោយផ្អែកលើតម្រូវការពិនិត្យលក្ខន្តិកៈ រចនាសម្ព័ន្ធប្រតិបត្តិនៃអង្គការ ការគ្រប់គ្រងធនធានមនុស្ស និតិវិធីភស្តុភា និងលទ្ធកម្ម ស្ថានការណ៍ខ្ទាតប្រាក់ខែនៅក្នុង API។

## មុខងារគ្រប់គ្រង

ខ្សែសង្វាក់បញ្ជាក្នុងចំណោមខ្សែបណ្តោយអ្នកគ្រប់គ្រងថ្នាក់កំពូល និងថ្នាក់កណ្តាលជាមួយមន្ត្រីជួរមុខជាច្រើនគួររៀបចំឡើងវិញដើម្បីសម្រាលភាពស្មុគស្មាញក្នុងលំដាប់ថ្នាក់អង្គការ និងប្រតិបត្តិ។ អ្នកគ្រប់គ្រងថ្នាក់កំពូល និងថ្នាក់កណ្តាលនានាគួរច្បាស់លាស់អំពីទិសដៅយុទ្ធសាស្ត្រដើម្បីដឹកនាំ/គ្រប់គ្រងអង្គការទាំងមូលឱ្យដើរទៅមុខ និងតួនាទីរបស់អ្នកគ្រប់គ្រងថ្នាក់កណ្តាលគួរមានប្រសិទ្ធភាពច្រើនជាងធម្មតាក្នុងការសម្រេចបានជោគជ័យជាច្រើនសម្រាប់អង្គការ។ ប្រការនេះក៏ទាក់ទងនឹងការរៀបចំបន្ទុកការងារលើសចំណុះរបស់នាយកប្រតិបត្តិ និងគណៈគ្រប់គ្រងផងដែរ ដើម្បីឱ្យពួកគាត់អាចផ្តល់ការគាំទ្រគ្រប់គ្រាន់ និងត្រួតពិនិត្យការងាររបស់អ្នកក្រោមបង្គាប់ដែលនាំឱ្យសម្រេចបានតាមកាលបរិច្ឆេទផុតកំណត់ និងមានសុក្រិតភាពសម្រាប់របាយការណ៍របស់ API។ ការប្តឹងតវ៉ា/យោបល់ត្រឡប់នានាពីបុគ្គលិកគួរតាមដានជាលក្ខណៈប្រព័ន្ធ និងដោះស្រាយដើម្បីធ្វើឱ្យច្បាស់លាស់ថា បញ្ហាអង្គការ និងប្រតិបត្តិជាច្រើនត្រូវបានដោះស្រាយដោយមានប្រសិទ្ធភាព និងប្រសិទ្ធផល។ ជាជាក់លាក់ មានតម្រូវការ៖

- ពង្រឹងការផ្ទេរការទទួលខុសត្រូវ/កិច្ចការជាច្រើន ភាពជាម្ចាស់ការរបស់បុគ្គលិក និងការចូលរួមក្នុងការសម្រេចចិត្តក្នុងគម្រោងរបស់ពួកគេរៀងៗខ្លួន។ ពង្រឹងការផ្ទេរការគាំទ្រពីក្រោយ និងការបង្ហាត់ដោយថ្នាក់គ្រប់គ្រង ឬអ្នកជំនាញបច្ចេកទេសខាងក្រៅដែលត្រូវផ្តល់ដល់បុគ្គលិកម្នាក់ៗដោយផ្អែកលើតម្រូវការ។ បន្ថែមពីលើនេះ កិច្ចប្រជុំសម្របសម្រួលកម្មវិធីប្រចាំសប្តាហ៍ទៀងទាត់ក្នុងចំណោមសមាជិកជាច្រើននៃគណៈគ្រប់គ្រងគឺត្រូវលើកស្ទួយដើម្បីធ្វើបច្ចុប្បន្នភាព និងសម្របសម្រួលសកម្មភាពគម្រោងនានា។
- ពង្រឹងការប្រាស្រ័យទាក់ទងដែលហួសពីវិធីពីលើចុះក្រោម ហើយប្រការនេះផ្តោតលើការស្តាប់ និងការលើកទឹកចិត្តសមាជិកក្រុម ជាច្រើនជាជាងបង្គាប់បញ្ជាពួកគេ។
- ពិចារណាកាត់បន្ថយជំហាននៃការច្នៃប្រឌិតថ្មី និងការផ្លាស់ប្តូរដែលបានប៉ុនប៉ងចង់ធ្វើ ដោយមិនទាមទារច្រើនពេកពីបុគ្គលិក (ដែលកំពុងផ្លាស់ប្តូរ)។
- ផ្តល់ឱកាសផ្ទៃក្នុងជាច្រើនសម្រាប់ការអភិវឌ្ឍការងារ ដោយការយកកិច្ចការថ្មីៗ តំណែងថ្មី ទៅតាមចំណាប់អារម្មណ៍របស់បុគ្គលិក។





# របាយការណ៍បីឆ្នាំ ២០១៩-២១

## គោលនយោបាយនានា

API មានគោលនយោបាយជាច្រើន។ វាត្រូវការណែនាំគោលនយោបាយទាំងនោះឡើងវិញដល់បុគ្គលិកឱ្យបានទៀងទាត់ និងគួរមានវគ្គទៀងទាត់ជាច្រើនជាមួយបុគ្គលិកដើម្បីរំលឹក/ពិនិត្យមើលគោនយោបាយផ្សេង។

វាត្រូវបានគេឱ្យអនុសាសន៍ថា API មានអ្នកបច្ចេកទេសជាច្រើនសម្រាប់ធ្វើការជាមួយពួកគេក្នុងរយៈពេលជាក់លាក់មួយ ដូចជា ៤-៦ ខែ ដើម្បីជួយ API ពិនិត្យ/ធ្វើបច្ចុប្បន្នភាពគោលនយោបាយចាំបាច់ជាច្រើនដូចតទៅ៖

- លក្ខន្តិកៈ (ឬសៀវភៅក្បួនស្តីពីក្រុមប្រឹក្សាភិបាល) ដើម្បីឆ្លុះបញ្ចាំងអំពីតួនាទី និងមុខងារដែលកើនឡើងរបស់ក្រុមប្រឹក្សាភិបាល នៃ API និងមានយន្តការចាំបាច់នានាដើម្បីគាំទ្រមុខងារក្រុមប្រឹក្សាភិបាល។
- គោលនយោបាយធនធានមនុស្ស (សៀវភៅគោលនយោបាយបុគ្គលិក) ដើម្បីគ្រប់គ្រងការបំពេញការងារបុគ្គលិកដើម្បីឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់បំផុត។ ការពិនិត្យធនធានមនុស្សនឹងមើលលើយន្តការវាយតម្លៃនានា (ជាពិសេស ដើម្បីផ្តោតលើកិច្ចសន្ទនារវាងបុគ្គលិក និងអ្នកគ្រប់គ្រងផ្ទាល់ ដូចជា ការកំណត់រួមគ្នានូវផ្នែកដែលត្រូវការសម្រាប់ការអភិវឌ្ឍសមត្ថភាព និងលើកទឹកចិត្តបុគ្គលិកឱ្យលូតលាស់[4] និងផ្តោតលើការពិនិត្យជាប្រព័ន្ធលើការបំពេញការងារបុគ្គលិក និងការអភិវឌ្ឍដែលផ្សាភ្ជាប់ជាមួយការលូតលាស់សក្តានុពលរបស់អង្គការ និងបរិបទអភិវឌ្ឍន៍ដែលកំពុងផ្លាស់ប្តូរដែលប៉ះពាល់ការងារបុគ្គលិកម្នាក់ៗ) និងខ្នាតប្រាក់ខែ (ដើម្បីឆ្លុះបញ្ចាំងអំពីការកើនឡើងនៃចំណាយជីវភាព ក៏ដូចជាការធ្វើឱ្យមានស្តង់ដារនូវកម្រិតឡើងប្រាក់ខែពីមួយកម្រិត/ថ្នាក់ទៅកម្រិតមួយទៀត)។
- គោលនយោបាយហិរញ្ញវត្ថុដើម្បីឆ្លុះបញ្ចាំងវិធីធ្វើការតាមអនឡាញ ដោយរួមទាំងធ្វើឱ្យសាមញ្ញនូវនីតិវិធីលទ្ធកម្ម និងភស្តុភារ (រួមទាំងការស្នើសុំ និងការទូទាត់តាមអនឡាញ) និងការធ្វើឱ្យមានស្តង់ដារនូវប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់សហគមន៍ដែលបានចូលរួមក្នុងព្រឹត្តិការណ៍របស់ API។
- បង្កើតគោលនយោបាយសម្រាប់ការលៃលកតម្លៃបដិភាគ។

គឺត្រូវការឱ្យមានការខំប្រឹងប្រែងខ្លាំងក្លាជាងធម្មតាមួយក្នុងការតម្រង់ទិស (ឬការដាក់បញ្ចូល) បុគ្គលិកថ្មីឱ្យដឹងពីគោលនយោបាយនានារបស់ API។ ការតម្រង់ទិសមិនគួរឱ្យបុគ្គលិកថ្មីចូលរួមតែថ្ងៃដំបូងនោះទេ ប៉ុន្តែគួរមានវគ្គបន្តបន្ទាប់ពីមួយសប្តាហ៍ មួយខែ និងក្រោយបញ្ចប់រយៈពេលសាកល្បង។

ប្រជុំទៀងទាត់ (ពីរឆ្នាំម្តង ឬរៀងរាល់ឆ្នាំ) នៃម្ចាស់ជំនួយរបស់ API សម្រាប់ការឆ្លុះបញ្ចាំងរួមគ្នាលើផ្នែកណាមួយនៃគោលនយោបាយដែលរារាំងប្រតិបត្តិការរបស់ API គួរត្រូវបានរៀបចំឡើងចាប់តាំងពីពេលដែល API មានម្ចាស់ជំនួយច្រើនសម្រាប់គម្រោង និងម្ចាស់ជំនួយខុសៗគ្នាដែលព្យាយាមបញ្ជ្រៀតគោលនយោបាយរបស់ពួកគេក្នុងរបៀបខុសគ្នាដែលនាំឱ្យមានការលំបាកច្រើនសម្រាប់ការអនុវត្តតាមរបស់ API។

## រចនាសម្ព័ន្ធប្រតិបត្តិ

ដោយសារតែមានការិយាល័យតែមួយនៅភ្នំពេញ ប្រតិបត្តិការបច្ចុប្បន្នហាក់ដូចជាមិនអាចធ្វើឱ្យ API ដំណើរការ និងគ្រប់គ្រងគម្រោងជាច្រើនរបស់ខ្លួន (ដែលភាគច្រើនបំផុត ប្រតិបត្តិការនៅតាមតំបន់ជនបទនានា) ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ជាពិសេសស ក្នុងអំឡុងពេលការរីករាលដាលជំងឺកូវីដ-១៩។ ចំពោះខេត្តមួយចំនួន API អាចប្រើឱ្យបានអតិបរមានូវការិយាល័យដៃគូសម្រាប់បុគ្គលិកគម្រោងរបស់ខ្លួនដែលបង្ហាញថាជាគំរូល្អក្នុងប្រតិបត្តិការរបស់ API។

# របាយការណ៍បីឆ្នាំ ២០១៩-២១

API អាចត្រូវធ្វើការសិក្សាហ្មត់ចត់ និងការវិភាគមួយអំពីតម្លៃដែលពាក់ព័ន្ធ និងប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងគម្រោងរបស់ខ្លួនដោយមានជម្រើសមួយ ដែលត្រូវបង្កើតការិយាល័យថ្នាក់តំបន់ ឬថ្នាក់ខេត្តមួយ។

## ក្របខ័ណ្ឌនៃការត្រួតពិនិត្យ ការវាយតម្លៃ គណនេយ្យភាព និងការរៀនសូត្រ (MEAL)

ប្រការសំខាន់គឺថា អង្គការអាចត្រួតពិនិត្យអ្វីដែលកំពុងកើតឡើង និងធ្វើការផ្លាស់ប្តូរបើត្រូវការ។ វាជាចំណុចសំខាន់មួយនៃក្របខ័ណ្ឌត្រួតពិនិត្យ ការវាយតម្លៃ គណនេយ្យភាព និងការរៀនសូត្រ (MEAL) នៅក្នុងអង្គការមួយ។ ក្របខ័ណ្ឌត្រួតពិនិត្យ ការវាយតម្លៃ គណនេយ្យភាព និងការរៀនសូត្រទូលំទូលាយមួយនឹងអាចឱ្យបុគ្គលិក API តាមដាន និងប្រមូលផ្តុំទិន្នន័យ (ទាំងការរីកចម្រើន និងកត្តាប្រឈម) តាមរយៈការអនុវត្តកម្មវិធី។ ក្របខ័ណ្ឌត្រួតពិនិត្យ ការវាយតម្លៃ គណនេយ្យភាព និងការរៀនសូត្រ (MEAL) អាចនឹងជួយបុគ្គលិកផងដែរក្នុងកាច់ចង្កូតសកម្មភាពរបស់ពួកគេ ក៏ដូចជាដោះស្រាយបញ្ហាផ្សេងៗនៅពេលដែលវាកើតឡើង។

API បានចុះកិច្ចសន្យាជួលមន្ត្រីឯកទេសខាងត្រួតពិនិត្យ ការវាយតម្លៃ គណនេយ្យភាព និងការរៀនសូត្រ (MEAL) ដើម្បីធ្វើឱ្យទម្រង់ត្រួតពិនិត្យ ការវាយតម្លៃ គណនេយ្យភាព និងការរៀនសូត្រ (MEAL) មានស្តង់ដារ។ វាចាំបាច់សម្រាប់ API ក្នុងការឱ្យបុគ្គលិកគម្រោងពាក់ព័ន្ធក្នុងដំណើរការធ្វើស្តង់ដារនៃត្រួតពិនិត្យ វាយតម្លៃ គណនេយ្យភាព និងរៀនសូត្រ (MEAL)។ ដំណើរការគួរបញ្ចូលការបញ្ជាក់ និងវិសោធនកម្មលើឧបករណ៍ប្រមូលទិន្នន័យសម្រាប់គោលបំណងជាក់លាក់ផ្សេងៗ និងធានាថាបុគ្គលិកទាំងអស់ស៊ាំនឹងឧបករណ៍ទាំងនោះ។ វាចាំបាច់ផងដែរចំពោះមន្ត្រីឯកទេសត្រួតពិនិត្យ វាយតម្លៃ គណនេយ្យភាព និងរៀនសូត្រ (MEAL) ត្រូវផ្តល់ការបង្ហាត់ដល់បុគ្គលិកគម្រោងរបស់ API ដើម្បីអភិវឌ្ឍ និងអនុវត្តឧបករណ៍ត្រឹមត្រូវដើម្បីប្រមូលទិន្នន័យដែលត្រឹមត្រូវ (ជាពិសេស ទិន្នន័យដែលទាក់ទងនឹងលទ្ធផល/ឥទ្ធិពលនៃសកម្មភាពគម្រោងរបស់ពួកគេ) និងវិភាគរកលក្ខណៈនៃទិន្នន័យឬលទ្ធផលចេញពីគម្រោងនីមួយៗទៅតាមលទ្ធផល និងឥទ្ធិពលដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្ររបស់ API។ បន្ទាប់ពីទម្រង់ត្រួតពិនិត្យ វាយតម្លៃ គណនេយ្យភាព និងរៀនសូត្រ (MEAL) ត្រូវបានបញ្ចប់ជាស្ថាពរ/ត្រូវបានអនុម័តហើយ ការគាំទ្រពិតៗដល់បុគ្គលិកក្នុងការអនុវត្តទម្រង់នេះ (ជាពិសេស ប្រព័ន្ធទិន្នន័យតាមអនឡាញ) និងឧបករណ៍ប្រមូលទិន្នន័យផ្សេងៗ និងឱ្យបុគ្គលិកពាក់ព័ន្ធក្នុងការឆ្លុះបញ្ចាំងទៀងទាត់មួយ (ដូចជា ដំណើរការ និងលទ្ធផលនានា) និងការពិនិត្យ/ការកែប្រែក្របខ័ណ្ឌត្រួតពិនិត្យ វាយតម្លៃ គណនេយ្យភាព និងរៀនសូត្រ (MEAL) គឺសំខាន់ណាស់។



# វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

## អង្គការមិនមែនរដ្ឋាភិបាលឈានមុខមួយ ដែលសកម្មនៅក្នុងការតស៊ូមតិ ការជះឥទ្ធិពលលើគោលនយោបាយ ការកសាងសមត្ថភាព អភិបាលកិច្ចល្អ និងការសម្របសម្រួលកិច្ចសន្ទនារវាងប្រជាពលរដ្ឋ និងតួអង្គរបស់រដ្ឋ

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) ជាអង្គការក្រៅរដ្ឋាភិបាលមួយរបស់កម្ពុជា ដែលសកម្មក្នុងការតស៊ូមតិ ការជះឥទ្ធិពលនយោបាយ អភិបាលកិច្ចល្អ និងការចូលរួមរបស់ពលរដ្ឋ។ ការកសាងសមត្ថភាព និងការសម្របសម្រួលកិច្ចសន្ទនា គឺជាចំណុចសំខាន់នៃកិច្ចខិតខំប្រឹងប្រែងរបស់យើង ឆ្ពោះទៅរកការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

យើងទទួលបានការសារទរយ៉ាងទូលំទូលាយពីអង្គការក្នុងស្រុក និងអន្តរជាតិសម្រាប់ភាពដែលអាចជឿជាក់បាន ភាពពាក់ព័ន្ធ និងវិជ្ជាជីវៈរបស់យើង។ ក្នុងរយៈពេលជិតពីរទសវត្សរ៍មកនេះ API បានជួយពង្រឹងជំនាញស្ថាប័នតស៊ូមតិ និងបានខិតខំធ្វើឱ្យលទ្ធិប្រជាធិបតេយ្យមូលដ្ឋាន និងអភិបាលកិច្ចដែលមានគណនេយ្យភាព ក្លាយទៅជាការពិត។ មកទល់នឹងពេលនេះ យើងបានបើកវគ្គបណ្តុះបណ្តាលជាង ៣០០ មកហើយ សម្រាប់អ្នកចូលរួមជាង ១ ម៉ឺននាក់ ដែលមានទំនាក់ទំនងជាមួយសង្គមស៊ីវិល និងអង្គការសហគមន៍ ក្រុមប្រឹក្សា មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ អង្គភាពសហជីព ស្ថាប័នរដ្ឋាភិបាល និងសភាកម្ពុជាផងដែរ។

API មានភាពប្លែកពីគេ នៅក្នុងសង្គមស៊ីវិលរបស់ប្រទេសកម្ពុជា ដោយបម្រើជាអ្នកភ្ជាប់ និងសម្របសម្រួល សម្រាប់ការផ្តល់សិទ្ធិអំណាចដល់ប្រជាជន ក្នុងការធ្វើអន្តរកម្មជាមួយរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់។ API ទទួលបានបទពិសោធន៍ដំបូង លើបញ្ហាគោលនយោបាយ ដូចជាការទទួលបានព័ត៌មាន (A2I) តាមរយៈការងារមូលដ្ឋានរបស់ខ្លួន។ ផ្អែកលើបទពិសោធន៍ដ៏ធំធេងនេះយើងស្ថិតក្នុងកន្លែងដ៏ល្អបំផុតមួយដើម្បីធ្វើឱ្យសំឡេងរបស់ពលរដ្ឋសាមញ្ញត្រូវបានរាប់បញ្ចូលក្នុងការធ្វើគោលនយោបាយនៅថ្នាក់ជាតិ។ នៅទីនេះយើងបានព្យាយាមគាំទ្រដល់ស្ថាប័នរដ្ឋាភិបាលឱ្យបម្រើប្រជាពលរដ្ឋស្របតាមច្បាប់ និងចូលរួមចំណែកក្នុងបរិយាកាស ដែលអាចឲ្យពលរដ្ឋ និងសង្គមស៊ីវិលអាចបង្ហាញការព្រួយបារម្ភរបស់ពួកគេបាន។ ទីបំផុត យើងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយពលរដ្ឋឱ្យយល់ពីសិទ្ធិរបស់ពួកគេ ការទទួលបានព័ត៌មាន និងប្រើប្រាស់ឱកាសសម្រាប់ការចូលរួម ដែលត្រូវបានផ្តល់ជូនដោយច្បាប់ផ្សេងៗ និងគោលនយោបាយរបស់រដ្ឋាភិបាល។

កម្មវិធីរបស់យើងត្រូវបានដឹកនាំដោយវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស។ API បម្រើប្រជាជនកម្ពុជាទាំងអស់ ហើយឱ្យតម្លៃទៅលើភាពខុសគ្នា ដោយមិនប្រកាន់ភេទ និន្នាការភេទ និងអត្តសញ្ញាណ ការមានសតម្លភាព ការអសមត្ថភាព ជាតិពន្ធុ ជំនឿ និងនិន្នាការនយោបាយឡើយ។ ទន្ទឹមនឹងនេះដែរ យើងមានការប្តេជ្ញាចិត្ត ជាពិសេស ក្នុងការគាំទ្រដល់អ្នកដែលជួបការលំបាកបំផុតក្នុងការខិតខំធ្វើឱ្យសំឡេងរបស់ពួកគេត្រូវបានគេដឹងឮ។

## ទំនាក់ទំនង

អគារ ភ្នំពេញវីឡា ផ្ទះលេខ ១២៤ ផ្លូវ ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ (៨៥៥-២៣) ២១៣ ៤៨៦ ទូរសារ (៨៥៥-២៣) ២១៣ ៤៨៧
www.apiinstitute.org